# ពិធីការសំរាប់ការបើកសាលា K-12 ឡុងប៊ីច ឡើងវិញ: ឧបសម្ព័ន្ធ X1

**ការកែប្រែថ្មីៗ:**

- 9/2/20 - ធ្វើបច្ចុប្បន្នភាព ដើម្បីបញ្ចូលការណែនាំរបស់រដ្ឋ ស្តីពីក្រុមមនុស្ស ឬសហករណ៍

**សាលារៀន K-12 ទាំងអស់ នៅខោនធីនានា ក្នុងរដ្ឋកាលីហ្វ័រញ៉ា នៅក្នុងចំណាត់ថ្នាក់ទី ១ នៃប្លង់មេរបស់រដ្ឋ សម្រាប់សេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន, រួមទាំងខោនធីឡូសអានចែលឡេស និងទីក្រុងឡុងប៊ីច, ត្រូវតែអោយនៅបិទនូវការរៀន ដោយមនុស្សផ្ទាល់ លើកលែង តែត្រូវបានអនុញ្ញាតិ បទបញ្ញាមានសុវត្ថិភាពជាង ពេលនៅផ្ទះ និងពិធីសារនេះ។ ដោយអនុលោមតាមបទបញ្ញានេះ, សាលា K-12 នៅខោនធីឡូសអានចែលឡេស, រួមបញ្ចូលទាំងនៅក្នុងក្រុងឡុងប៊ីច, អាចនឹងបើកសម្រាប់តែការសិក្សាពីចម្ងាយប៉ុណ្ណោះ ជាមួយនឹងការលើកលែងដែលមានកំណត់ ដែលបានពិភាក្សា ដូចខាងក្រោម។**

សាលារៀន K-12 ទាំងអស់ នៅខោនធីនានា ក្នុងរដ្ឋកាលីហ្វ័រញ៉ា ដែលស្ថិតនៅក្នុងបញ្ជីត្រួតពិនិត្យ COVID-19 របស់រដ្ឋ, ដែលរួមបញ្ចូលទាំងខោនធីឡូសអានចែលឡេស, ត្រូវបានហាមឃាត់ មិនអោយបើកឡើងវិញសម្រាប់ការបង្រៀនដោយផ្ទាល់។ ដោយអនុលោមតាមបទបញ្ញានេះ, សាលា K-12 នៅខោនធីឡូសអានចែលឡេស, អាចនឹងបើកសម្រាប់តែការសិក្សាពីចម្ងាយប៉ុណ្ណោះ។ ក្នុងអំឡុងពេលនេះ, និយោជិក និងបុគ្គលិក, ដែលបានកំណត់ដូចខាងក្រោម, អាចរាយការណ៍ ឬបង្ហាញខ្លួនទៅកាន់បរិវេណសាលា សម្រាប់ការងារដើម្បីគាំទ្រដល់ការអនុវត្តការសិក្សាពីចម្ងាយ និងដើម្បីគាំទ្រដល់ប្រតិបត្តិការសាលារៀនមូលដ្ឋានផ្សេងទៀត។ ត្រូវអនុវត្តនូវរាល់វិធានការណ៍ដែលអាចអនុវត្តបាន នៅក្នុងពិធីសារនេះដើម្បីធានាសុវត្ថិភាពដល់និយោជិក។ ការលើកលែង សម្រាប់ការបើកការអប់រំបឋម (ធីខេ រហូតដល់ថ្នាក់ទី ៦) បច្ចុប្បន្ន មិនត្រូវបានអនុញ្ញាតិទេ, ទោះបីជាយ៉ាងណា ព័ត៌មានបន្ថែមអំពីដំណើរការលើកលែង, ដែលអាចនឹងដំណើរការនាពេលអនាគត។

LONG BEACH HEALTH & HUMAN SERVICES

នៅក្នុងអំឡុងពេលដែល ពេលសាលារៀនបើកសម្រាប់ការរៀនសូត្រពីចម្ងាយ, អនុញ្ញាតិអោយមានការថែទាំយកចិត្តទុកដាក់ចំពោះកុមារដែលមានអាយុចូលរៀន ដោយអនុលោមតាម [ពិធីសារ LBDHHS សម្រាប់កម្មវិធីផ្តល់ការថែទាំប្រចាំថ្ងៃសម្រាប់កុមារ ដែលមានអាយុចូលសាលារៀន]។ គំរូនានាខាងក្រោម សម្រាប់ការផ្តល់ការថែទាំបែបនេះនៅលើបរិវេណសាលា គឺអាចអនុញ្ញាតិបាន។ ម៉ូដែលបន្ថែមទៀត អាចត្រូវបានបន្ថែម នៅពេលដែលព័ត៌មានបន្ថែមនានាទៀត ត្រូវបានផ្តល់ជូនតាមរយៈនាយកដ្ឋានសុខាភិបាលរដ្ឋកាលីហ្វ័រញ៉ា, នាយកដ្ឋាននៃសេវាសង្គមរដ្ឋកាលីហ្វ័រញ៉ា, និងនាយកដ្ឋានអប់រំរដ្ឋកាលីហ្វ័រញ៉ា (CDE)។

- អ្នកផ្តល់សេវា ECE ដែលមានអាជ្ញាប័ណ្ណ, រួមបញ្ចូល ទាំងអ្នកដែលមានអាជ្ញាប័ណ្ណរួមមានការមើលថែក្មេង ដែលមានអាយុចូលរៀន;
- និយោជកណា ដែលទទួលបានការលើកលែងជាបន្ទាន់ ពីផ្នែកផ្តល់អាជ្ញាប័ណ្ណថែទាំសហគមន៍ (CCLD) សម្រាប់ប្រតិបត្តិការ នៃការថែទាំកុមារ ដែលមានការឧបត្ថម្ភដោយនិយោជិក។
  - ប្រសិនបើអ្នកជានិយោជិក ដែលកំពុងស្វែងរកការលើកលែងជាបន្ទាន់ សម្រាប់គោលបំណងនេះ, សូមទាក់ទងការិយាល័យ CCLD ក្នុងតំបន់របស់អ្នក។ ព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យ អាចរកបាននៅ[ទីនេះ]។
- ការពង្រីកកម្មវិធីសិក្សា ដែលបានផ្តល់មូលនិធិដោយ CDE ដូចជា ការអប់រំ និងសុវត្ថិភាពក្រោយការសិក្សា (ASES), មជ្ឈមណ្ឌលសិក្សាសហគមន៍នៅសតវត្សទី ២១ (21st CCLC), វិទ្យាល័យក្រោយសតវត្សទី ២១ សុវត្ថិភាព និងការលើកកម្ពស់សម្រាប់យុវជន (ASSETs)។ [សូមមើល នាយកដ្ឋានអប់រំរដ្ឋកាលីហ្វ័រញ៉ា [សំណួរដែលសួរជាញឹកញាប់ អំពីជំងឺ COVID-19 ឆ្នាំ ២០២០-២១]]

ខណៈពេលដែលសាលារៀនត្រូវបានបិទ ចំពោះការបង្រៀនក្នុងថ្នាក់ទាំងអស់, ការវាយតម្លៃដោយផ្ទាល់ ត្រូវបានអនុញ្ញាតិនៅតាមបរិវេណសាលា សម្រាប់និស្សិតដែលមាន ឬដែលតម្រូវឱ្យមានការវាយតម្លៃសម្រាប់ផែនការអប់រំលក្ខណៈបុគ្គល (IEPs) នៅពេលដែលការវាយតម្លៃបែបនេះ មិនអាចអនុវត្តបាន នៅកន្លែងផ្សេងទៀត។

ខណៈពេលដែលសាលារៀន ត្រូវបានបិទសម្រាប់ការបង្រៀនថ្នាក់រៀន ទីភ្នាក់ងារអប់រំទាំងអស់ ក្នុងតំបន់, រួមទាំងសាលារដ្ឋ និងសាលាឯកជន, ត្រូវបានអនុញ្ញាតិឱ្យផ្តល់ជាក្រុមតូចៗ, សេវាកម្មផ្ទាល់ខ្លួនដែលមានការគ្រប់គ្រង, ត្រួតពិនិត្យ និងបរិស្ថានក្នុងផ្ទះសម្រាប់សេវាកម្មជំនាញ, សេវាកម្មគោលដៅ និងការគាំទ្រដល់និស្សិត ក្នុងន័យដែលរក្សាការផ្តោត ការយកចិត្តទុកដាក់ លើសុខភាព និងសុវត្ថិភាពដើម្បីកាត់បន្ថយការឆ្ល

ង។ សេវាកម្មទាំងនេះ ត្រូវផ្តល់ជូនដល់ក្រុមមនុស្សដែលជានិស្សិត/ក្រុមនិស្សិត ដែលមានស្ថេរភាព (ឬមិនចេញចូល) មិនលើសពី ១៤ នាក់ ដែលមានបុគ្គលិកត្រួតពិនិត្យ មិនលើសពី ២ នាក់ និងមិនលើសពី ២៥% នៃអគារស្នាក់នៅ។ សូមមើល CDPH ការណែនាំសំរាប់ក្រុមមនុស្ស ឬសហករណ៍/ក្រុមកុមារ និងយុវជនតូចៗ, និង សំណួរដែលបានគេសួរញឹកញាប់ អំពីការផ្តល់ជូនជាគោលដៅ, ការគាំទ្រពិសេស និងសេវាកម្មនានា នៅតាមសាលារៀន សំរាប់ពត៌មានពិស្តារ។ ពិធីសារបើកសារឡើងវិញនេះ ត្រូវតែបានអភិវឌ្ឍន៍, អនុវត្ត, និងអនុលោមតាម ក្នុងគោលបំណងដើម្បីផ្តល់នូវសេវាផ្ទាល់ខ្លួនទៅកាន់ក្រុមនិស្សិតក្រុមតូចៗ។

នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស (នាយកដ្ឋានសុខាភិបាល) ឡុងប៊ិច កំពុងអនុវត្តនូវវិធីសាស្ត្រដែលមានជាដំណាក់កាល, ដែលមានការគាំទ្រដោយជំនាញវិទ្យាសាស្ត្រ និងសុខភាពសាធារណៈ, ដើម្បីអោយសាលារៀនអាចផ្តល់សេវាកម្មដល់សិស្ស ចាប់ពីមត្តេយ្យ ដល់ថ្នាក់ទី ១២ ដើម្បីបើកបើកឡើងវិញ ប្រកបដោយសុវត្ថិភាព។ បន្ថែមលើល័ក្ខខ័ណ្ឌនានា ដែលបានដាក់ទៅលើសាលារៀន ដោយមន្ត្រីសុខភាពសាធារណៈរដ្ឋ និងក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា, ផងដែរ សាលារៀនក៏ត្រូវគោរពតាម ពិធីសារនៃការគ្រប់គ្រងសុវត្ថិភាពនិយោជិក និងសិស្ស និងការគ្រប់គ្រងការឆ្លង ទាំងនេះផងដែរ។

សូមសំគាល់: ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមាននូវព័ត៌មាន និងធនធានថ្មីៗ។ ចូលទៅកាន់ www.longbeach.gov/covid19 ដើម្បីព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ:

1. គោលនយោបាយនានា និងការអនុវត្តនានានៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក និងសិស្ស
2. វិធានការណ៍នានា ដើម្បីធានាបាននូវគំលាតរាងកាយពីគ្នា
3. វិធានការណ៍នានា ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លង
4. ការប្រាស្រ័យទាក់ទងជាមួយនិយោជិក, សិស្ស និងគ្រួសារនៃសិស្ស និងសាធារណៈជន
5. វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍន៍នូវពិធីការបើកឡើងវិញនោះ។

សាលា ត្រូវអនុវត្តនូវរាល់វិធានការណ៍ទាំងអស់ដែលអាចអនុវត្តបាន ដែលមានរាយខាងក្រោម ហើយត្រៀមក្នុងការពន្យល់អំពីមូលហេតុអ្វី បានជាវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្តនោះ មិនអាចអនុវត្តបាន។

**ឈ្មោះស្ថាប័ន:**

___

**អាស័យដ្ឋាន:**

___

**សំគាល់:** ពាក្យ "និយោជិក" និង "បុគ្គលិក" ត្រូវបានប្រើនៅក្នុងពិធីសារទាំងនេះ ដើម្បីសំដៅទៅលើឯកត្តបុគ្គល ដែលធ្វើការនៅក្នុងគ្រឹះស្ថានសិក្សា ក្នុងសមត្ថភាពណាមួយ ដែលទាក់ទងទៅនឹងការបង្រៀន, ការបម្រើក, ការគាំទ្រ ដល់សិស្ស, ការផ្តល់ការព្យាបាល ឬជំនួយផ្ទាល់ខ្លួនដល់សិស្សម្នាក់ៗ, ការសំអាត ឬការថែទាំកន្លែង, រដ្ឋបាល, ឬ សកម្មភាពផ្សេងទៀត ដែលត្រូវការ ដើម្បីអោយសាលារៀនដំណើរការ។ "និយោជិក" ឬ "បុគ្គលិក" អាចរាប់បញ្ចូល នូវឯកត្តបុគ្គល ដែលជាៈ បង់/ផ្តល់ឈ្នួលដោយផ្ទាល់តាមប្រព័ន្ធសាលារៀនពាក់ព័ន្ធ, បង់ដោយអង្គភាពនានា ដែល ដើរតួជាអ្នកម៉ៅការសាលា, បង់ដោយអង្គភាពខាងក្រៅដែលធ្វើកិច្ចសហការជាមួយសាលាដើម្បីបម្រើសិស្ស, បង់ ដោយភាគីទីបី ដើម្បីផ្តល់សេវាកម្មសិស្សម្នាក់ៗ, ឬអ្នកស្ម័គ្រចិត្តដែលមិនបានទទួលប្រាក់កម្រៃ ដែលកំពុងបំពេញ ការងារក្រោមការណែនាំរបស់សាលា ដើម្បីបំពេញមុខងារសំខាន់ៗ។ ពាក្យ "ឪពុកម្តាយ" ត្រូវបានប្រើនៅក្នុងពិធី សារទាំងនេះ ដើម្បីសំដៅទៅលើបុគ្គលណាម្នាក់ ដែលបម្រើការជាអ្នកមើលថែឬអាណាព្យាបាលចំពោះ/ដល់សិស្ស។

## A. គោលនយោបាយ និងការអនុវត្តនានានៅកន្លែងធ្វើការ ដើម្បីការពារបុគ្គលិក ("និយោជិក") និង សិស្ស

- សាលារៀន មាន**ផែនការគ្រប់គ្រងការប្រឈមនឹងជំងឺ COVID-19** (មើលទំព័រ ១៦) ដែលពិពណ៌នាអំពីវិធីសាស្រ្តដ៏ទូលំទូលាយរបស់សាលា ដើម្បីការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងបរិវេណសាលា។
- បង្កើតផែនការសហការណ៍រួម។ ផែនការសហការណ៍ ត្រូវតែរាប់បញ្ចូលជំហ៊ាននានា ដែលនឹងត្រូវអនុវត្តន៍ភ្លាមៗ នៅពេលមានការជូនដំណឹងពីមន្រ្តីសាលារៀនថា សមាជិកនៃសហគមន៍សាលារៀន (មហាវិទ្យាល័យ, បុគ្គលិក, សិស្ស ឬភ្ញៀវ) ធ្វើតេស្តមានវិជ្ជមាន, ឬមានរោគសញ្ញានានា ស្របគ្នាទៅនឹងជំងឺ COVID-19 (ដែលសំដៅថាជា "ករណី")។ ផែនការ ត្រូវតែដោះស្រាយដូចខាងក្រោមៈ
    - បំបែកករណីភ្លាមៗពីសហគមន៍សាលារៀន ដើម្បីដាក់ខ្លួនឯងអោយនៅឯកោនៅផ្ទះ ប្រសិនបើមានការជូនដំណឹងកើតឡើងខណៈពេលដែលករណីនោះ នៅនឹងកន្លែង/សាលា។ ផែនការត្រូវតែអនុញ្ញាតិអោយដាក់ខ្លួនអោយនៅឯកោ និងបណ្តោះអាសន្ននៅនឹងកន្លែង នៃករណី ប្រសិនបើមានតំរូវការក្នុងការរៀបចំ សំរាប់ការវិលត្រឡប់របស់បុគ្គលនោះ ទៅផ្ទះរបស់គេវិញ។

- សន្លឹកការពិត ឬសម្ភារៈព័ត៌មានផ្សេងៗ ដែលត្រូវផ្តល់ទៅអោយករណី (ឬសមាជិកគ្រួសារមួយ ឬច្រើនសមស្រប ប្រសិនបើករណី ជាកុមារ) គ្របដណ្តប់ ឬមាននូវបទប្បញ្ញត្តិគ្រប់គ្រងការដាក់ខ្លួនឯងអោយនៅឯកោ និងតំណរភ្ជាប់ទៅកាន់គេហទំព័រនានា ដែលមានព័ត៌មានបន្ថែម។
- ផែនការផ្តួចផ្តើមគម្រោងគ្រប់គ្រងការប្រឈមទៅនឹងជំងឺ COVID-19 ដែលបង្ហាញពីនីតិវិធីសម្រាប់:
  - បំបែក ឬការដាក់អោយនៅឯកោ នៃករណី (ច្រើន);
  - ការកំណត់អត្តសញ្ញាណមនុស្សដែលបានប្រឈម ទៅនឹងករណីនៅសាលា;
  - ការដាក់ខ្លួនអោយនៅឃ្លាតឆ្ងាយ ឬការធ្វើចត្តាឡីស័ក ពីនិយោជិក និង/ឬសិស្ស ដែលមានការប្រឈម ឬបានប៉ះពាល់  ជាបន្ទាន់; និង
  - ការធានានៃការទទួលបាន នូវការធ្វើតេស្ត សម្រាប់បុគ្គលដែលបានប្រឈមទាំងអស់ នៅក្នុងសាលា ជាមូលដ្ឋានសម្រាប់វិធានការណ៍គ្រប់គ្រងបន្ថែម។
- ផែនការដើម្បីរាយការណ៍ នូវចង្កោមនៃករណីច្រើន (៣ ករណី ឬច្រើនជាងនេះ ក្នុងរយៈពេល ១៤ ថ្ងៃ) ទៅកម្មវិធីត្រួតពិនិត្យជំងឺឆ្លង LBDHHS តាមលេខ (៥៦២) ៥៧០-៤៣០២។
- ផែនការសម្របសម្រួលសំរាប់ការបិទសាលារៀនទាំងស្រុង ឬផ្នែកខ្លះ នៃប្រតិបត្តិការសាលារៀនដោយមនុស្សផ្ទាល់ ប្រសិនបើវាក្លាយមកជាការចាំបាច់ ដោយផ្អែកលើការផ្ទុះឡើងនៅក្នុងសាលារៀន ឬសហគមន៍។

☐ ផែនការធ្វើតេស្ត សំរាប់ដាក់បញ្ចូលនូវការធ្វើតេស្តតាមដានមើល ចូលទៅក្នុងប្រតិបត្តិការសាលារៀន ជាទៀងទាត់ ចំពោះ/ទៅលើបុគ្គលិកសាលារៀនទាំងអស់។

- ផែនការធ្វើតេស្ត ត្រូវតែរួមបញ្ចូលនូវយុទ្ធសាស្ត្រមួយ សម្រាប់ធានានូវការទទួលបាន ការធ្វើតេស្តតាមកាលកំណត់ សម្រាប់បុគ្គលិកសាលាទាំងអស់ដែលត្រូវអនុវត្ត នៅពេលដែលមានសេចក្តីណែនាំដោយនាយកដ្ឋានសុខាភិបាល ដោយផ្អែកលើនិន្នាការជំងឺក្នុងតំបន់ និង/ឬបន្ទាប់ពីការដោះស្រាយការផ្ទុះឡើងនៅឯសាលារៀន ឬស្របតាមតម្រូវការនៃ COVID 19 និងក្របខ័ណ្ឌបើកសាលារៀន K12 ឡើងវិញ ក្នុងរដ្ឋកាលីហ្វ័រញ៉ា.
- សាលារៀនត្រូវបានណែនាំអោយធ្វើការជាមួយផែនការវេជ្ជសាស្ត្ររបស់បុគ្គលិក និងណែនាំប្រសិនបើ ផែនការវេជ្ជសាស្ត្រ មិនអនុញ្ញាតិ ឬមិនព្រមទទួលការធ្វើតេស្តនេះ។ ផងដែរ សាលារៀនក៏អាចកំណត់ថា ការចុះកិច្ចសន្យាជាមួយអ្នកផ្តល់ការធ្វើតេស្តភាគីទីបី អាចមានប្រយោជន៍

ហើយនេះអាចទទួលយកបាន ដែលមានន័យថា ការធ្វើតេស្តអង្គបដិប្រាណ មិនត្រូវបានប្រើប្រាស់ឡើយ។ រដ្ឋផ្តល់ជូននូវ បញ្ជីក្រុមការងារមន្ទីរពិសោធន៍ធ្វើតេស្ត ដែលអាចស្វែងរកបាន, ប៉ុន្តែមន្ទីរពិសោធន៍ ឬអ្នកផ្តល់ការធ្វើតេស្តដែលមានអាជ្ញាប័ណ្ណ ពីរដ្ឋកាលីហ្វ័រញ៉ាណាមួយក៏ដោយ គឺអាចទទួលយកបាន។

- និយោជិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, និងអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ ដែលនឹងធ្វើអោយពួកគេ ស្ថិតក្នុងហានិភ័យខ្ពស់ ប្រសិនបើបានឆ្លង) ត្រូវបានចាត់តាំងអោយធ្វើការ ដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។ និយោជិកប្រភេទនេះ គួរតែពិភាក្សាអំពីការព្រួយបារម្ភណាមួយជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ឬសេវាកម្មសុខភាពវិជ្ជាជីវៈរបស់ពួកគេ ដើម្បីធ្វើការសម្រេចចិត្តសមស្របក្នុងការត្រឡប់ទៅកាន់កន្លែងធ្វើការឡើងវិញ។
- ដំណើរការការងារ ត្រូវបានកំណត់ឡើងវិញក្នុងកំរិតមួយ ដែលត្រូវនឹងតម្រូវការនៃសិក្សា និងតម្រូវការរបស់សិស្ស ដើម្បីបង្កើនឱកាសនានាសម្រាប់និយោជិក ក្នុងការធ្វើការងារពីផ្ទះ។
- ដោយអនុលោមតាមបទប្បញ្ញត្តិប្រាក់ឈ្នួល និងម៉ោង និងអាណត្តិសាលារៀន, ការផ្លាស់ប្តូរកាលវិភាគ, ផ្លាស់វេនគ្នា ឬវេនបន្តបន្ទាប់គ្នា ត្រូវបានបង្កើតឡើង ដើម្បីបង្កើន/ពន្លាតចំងាយរាងកាយអោយបានអតិបរិមា តាមដែលអាចធ្វើទៅបាន។
- និយោជិកទាំងអស់ត្រូវបានគេប្រាប់ មិនអោយមកធ្វើការ ប្រសិនបើឈឺ, ឬប្រសិនបើពួកគេត្រូវបានប្រឈម នឹងអ្នកដែលមានជំងឺ C COVID-19។ មន្ត្រីសាលា បានផ្តល់ព័ត៌មានដល់និយោជិ កទាក់ទងនឹង អត្ថប្រយោជន៍ឈប់សម្រាក ដែលមានការឧបត្ថម្ភដោយនិយោជិក ឬដោយរដ្ឋាភិបាល, រួមទាំងសិទ្ធិរបស់ពួកគេក្នុងការឈប់សំរាក ឈឺដែលមានប្រាក់ឈ្នួល ដែលត្រូវបានធានាដោយច្បាប់ឆ្លើយតបជំងឺខ្សូណាវីរុសគ្រួសារជាចំបង។
- ការប្រើទីតាំងសាលាសម្រាប់គោលបំណងមិនមែនសាលារៀន (ការប្រជុំសហគមន៍ ឬព្រឹត្តិការណ៍នានា, ការចុះពិនិត្យ/ទស្សនាគ្លីនិកនៅនឹងកន្លែង ដោយមនុស្ស ដែលមិនមែនជាសិស្ស និងបុគ្គលិកជាដើម ។ល។) មិនត្រូវបានអនុញ្ញាតិឡើយ។
- ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិកអាចចូលកន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬឆែកឆេរទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់, ពិបាកដកដង្ហើម និងគ្រុនក្តៅ ឬគ្រុនញាក់, ឬគ្រុន និងរោគសញ្ញាផ្សេងៗទៀត ដែលកម្មករកំពុងជួបប្រទះ និងថាតើនិយោជិក បានមានទំនាក់ទំនងជាមួយមនុស្សដែលត្រូវបានគេស្គាល់ ឬសង្ស័យថា បានឆ្លងជំងឺ COVID-19 ក្នុងរយៈពេល ១៤ ថ្ងៃ ចុងក្រោយ។ ការត្រួតពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយមុនពេលនិយោជិកចាកចេញពីផ្ទះ ឬដោយ

ផ្ទាល់ នៅពេលមកដល់របស់និយោជិក។ ការត្រួតពិនិត្យសីតុណ្ហភាពជាមួយទែម៉ូម៉ែត្រមិនប៉ះពាល់ គួរតែត្រូវបានធ្វើ នៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។

- អ្នកណាម្នាក់ចូលទ្រព្យសម្បត្តិសាលារៀន (រួមទាំងឡានក្រុងសាលារៀន ក៏ដូចជាអាគារសាលារៀន និងទីធ្លា) ដែលមានទំនាក់ទំនងជាមួយអ្នកដទៃ (សិស្ស, ឪពុកម្តាយ ឬនិយោជិកផ្សេងទៀត) មានតំរូវការអោយពាក់គម្របមុខក្រណាត់។
    - និយោជិក ត្រូវបានគេផ្តល់ជូននូវគម្របមុខក្រណាត់មួយ ដោយឥតគិតថ្លៃ។ គម្របមុខ ត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅនឹងកន្លែង/សាលា ក្នុងខណៈពេលទំនាក់ទំនង ឬទំនងជាទាក់ទងជាមួយអ្នកដទៃ។ និយោជិក មិនត្រូវពាក់គម្របមុខក្រណាត់ឡើយ ពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬស្តង់ ឬគូបមានជញ្ជាំងឡើយ។
    - ម៉ាស់ដែលចំណាត់ថ្នាក់វេជ្ជសាស្រ្ត និងការការពារភ្នែក ត្រូវបានផ្តល់ជូនដល់និយោជិកណា ដែលមើលថែកុមារឈឺ ឬអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយកុមារណា ដែលមានលក្ខ័ណសុខភាពដែលរារាំងនូវការប្រើគម្របមុខក្រណាត់ របស់កុមារ។
    - យុទ្ធសាស្រ្តការពារជំនួស អាចត្រូវបានអនុម័ត/បង្កើតឡើង ដើម្បីសំរុះសំរួលសិស្ស ដែលមានការអប់រំលក្ខណៈបុគ្គល ឬផែនការ ៥០៤ និងអ្នកដែលមិនអាចប្រើប្រាស់ ឬអត់ទ្រាំនឹងការបិទបាំងគម្របមុខក្រណាត់បាន។
    - អ្នកដែលត្រូវបានលើកលែង ពីការពាក់គម្របមុខ ដោយសារលក្ខ័ណសុខភាព ដែលត្រូវបានជួលអោយធ្វើការ ដែលមានការទាក់ទងយ៉ាងទៀងទាត់ជាមួយអ្នកដទៃ ត្រូវតែពាក់នូវជម្រើសដែលមិនរឹតត្បិត, ដូចជា ខែលការពារមុខដែលមានក្រវ៉ាត់នៅលើគែមខាងក្រោម, ដរាបណា លក្ខខ័ណ្ឌរបស់ពួកគេ អនុញ្ញាតិអោយ។
    - និយោជិកត្រូវបានណែនាំអោយបោកសំអាត គម្របមុខជារៀងរាល់ថ្ងៃ។ ឪពុកម្តាយត្រូវបានណែនាំអោយធានាថា កុមារមានគម្របមុខស្អាត។
- ស្ថានីយ៍កន្លែងធ្វើការរបស់បុគ្គលិកម្នាក់ៗ ឬតំបន់ដែលត្រូវបានប្រើដោយនិយោជិក ដែលធ្វើការជាផ្នែកនៃក្រុម អនុញ្ញាតិអោយនៅឆ្ងាយពីគ្នា យ៉ាងហោចណាស់ ៦ ហ្វីត។ គ្រឿងសង្ហារឹមក្នុងថ្នាក់រៀន ត្រូវបានរៀបចំដើម្បីអនុញ្ញាតិអោយមានចម្ងាយយ៉ាងតិច ៦ ហ្វីត រវាងតុរបស់គ្រូ និងសិស្សនានា ដែលនៅជិតបំផុត។
- ដោយអនុលោមតាមបទប្បញ្ញត្តិប្រាក់ឈ្នួល និងម៉ោង, ការសំរាក ត្រូវបានដាក់អោយធ្វើបន្តបន្ទាប់គ្នា ដើម្បីធានាអោយមានការរក្សានបាននូវ ចំងាយឃ្លាតឆ្ងាយរាងកាយពីគ្នា នៅក្នុងបន្ទប់សម្រាក។ ពិចារណា

ផ្លាស់ប្តូរកន្លែងសំរាកអោយទៅខាងក្រៅ, ឬនៅតំបន់ដែលមានខ្យល់ចេញចូលល្អ ដូចជាបើកបង្អួច និងទ្វារនានា។

- និយោជិក, អ្នកម៉ៅការនៅកន្លែង, អ្នកលក់ និងបុគ្គលិកចែកចាយទាំងអស់ ត្រូវបានផ្តល់នូវការណែនាំទាក់ទងទៅនឹងការថែរក្សានូវចំងាយឃ្លាតឆ្ងាយរាងកាយពីគ្នា និងតំរូវការនៃការប្រើប្រាស់គម្របមុខ ពេលនៅជុំវិញអ្នកដទៃ។
- កន្លែងទូទៅដែលបានប្រើ ឬបានទស្សនាដោយបុគ្គលិក ត្រូវបានរំងាប់មេរោគបានយ៉ាងញឹកញាប់ តាមកាលវិភាគទៀងទាត់, យ៉ាងហោចណាស់ជារៀងរាល់ថ្ងៃ។ នេះរួមបញ្ចូលទាំង:
    - បន្ទប់សំរាក
    - បន្ទប់ទឹក
    - បន្ទប់រៀន
    - មន្ទីរពិសោធន៍
    - ការិយាល័យគិលានុបដ្ឋាយិកា
    - តំបន់ផ្តល់ប្រឹក្សា និងគាំទ្រផ្សេងៗដល់សិស្ស
    - ការិយាល័យខាងមុខ
    - ការិយាល័យផ្សេងៗ
- កន្លែងប៉ះច្រើន នៅក្នុងបន្ទប់សំរាករបស់បុគ្គលិក បានត្រូវរំងាប់មេរោគអោយបានញឹកញាប់។ របស់របរដែលបានចែករំលែកជាទូទៅ, ដូចជាភាជនៈ/ផើងកាហ្វេ, ផើង, និងចាន, ត្រូវបានជំនួសដោយរបស់របរប្រើប្រាស់តែម្តង។
- មាននូវទឹកផ្សើអនាម័យដែមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺ COVID-19 សម្រាប់បុគ្គលិកទាំងអស់ នៅក្នុង ឬនៅជិត ទីតាំងខាងក្រោមៈ
    - ច្រកចូល/ច្រកចេញអាគារ (ច្រើន)
    - ការិយាល័យកណ្តាល
    - ផ្លូវចូលជណ្តើរ
    - ផ្លូវចូលជណ្តើយន្ត (បើមាន)
    - ថ្នាក់រៀន
    - បន្ទប់សំរាកមហាវិទ្យាល័យ
    - ការិយាល័យមហាវិទ្យាល័យ
- មានសាប៊ូ និងទឹកសម្រាប់បុគ្គលិកទាំងអស់
- និយោជិក ត្រូវបានផ្តល់ឱកាសអោយលាងដៃរបស់ពួកគេបានញឹកញាប់។
- និយោជិកម្នាក់ៗត្រូវបានចាត់ចែងអោយនូវឧបករណ៍, គ្រឿងផ្គត់ផ្គង់, សំភារៈផ្ទាល់ខ្លួននានារបស់ពួកគេ និងបានកំណត់នូវកន្លែងធ្វើការ តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ការចែករំលែកកន្លែងធ្វើការ និងរបស់របរដែលយកទៅទុក ត្រូវបានកាត់បន្ថយ ឬលុបចោល។

- ច្បាប់ចតចំលងនៃពិធីសារនេះ ត្រូវតែមានសម្រាប់និយោជិក និងឪពុកម្តាយទាំងអស់ តាមការស្នើសុំនិង ផ្សព្វផ្សាយលើគេហទំព័ររបស់សាលារៀន។
- បង្កើត និងអនុវត្តកម្មវិធីចាក់ថ្នាំបង្ការជំងឺផ្តាសាយ (ការអប់រំការចាក់ថ្នាំបង្ការ, ការផ្សព្វផ្សាយ, និងការរៀបចំ ទុកដាក់ឯកសារនៃការចាក់ថ្នាំបង្ការ ដែលបានបញ្ចប់, ការចាក់ថ្នាំបង្ការបច្ចុប្បន្ន) ជាមួយគោលដៅនៃការ ចាក់ថ្នាំបង្ការគ្រុនផ្តាសាយធំ សម្រាប់សិស្ស និងបុគ្គលិកទាំងអស់ លើកលែងតែមានចងក្រងជាឯកសារ ប្រាប់នូវបម្រាម បញ្ជាក់ពីការលើកលែងនូវការចាក់ថ្នាំបង្ការជំងឺផ្តាសាយ, មុនពេល ឬនៅពេលចាប់ផ្តើម នៃ រដូវផ្តាសាយធំ (ជាធម្មតាចាប់ផ្តើម ពីថ្ងៃទី ១ ខែវិច្ឆិកា) ដើម្បីជួយ:
  - ការពារសហគមន៍សាលារៀន ពីជំងឺផ្តាសាយធំ, និងការឆ្លងរួមបញ្ចូលគ្នា ជាមួយវីរុសផ្តាសាយធំ និង COVID-19
  - កាត់បន្ថយនូវតំរូវការកន្លែងថែទាំសុខភាព
  - កាត់បន្ថយនូវជំងឺនានា ដែលមិនអាចត្រូវបានសម្គាល់យ៉ាងងាយស្រួលពីជំងឺ COVID-19 ហើយ ដែលនឹងបង្ករ ឬបណ្តាលអោយមានវិធានការណ៍យ៉ាងទូលំទូលាយពីសាលារៀន និងអាជ្ញាធរ សុខភាពសាធារណៈ។
- សាលារៀនត្រូវចុះឈ្មោះបុគ្គលិក នៅក្នុងកម្មវិធី វគ្គបណ្តុះបណ្តាលការតាមដានរកទំនាក់ទំនង (ជម្រើស ផ្សេងៗទៀត គឺមានការផ្តល់ជូន តាមអ៊ិនធឺណិត) មុនពេលបើកសារឡើងវិញ។

---

## B. វិធានការណ៍នានា ដើម្បីធានាបាននូវគំលាតរាងកាយពីគ្នា ដោយបុគ្គលិក, សិស្ស, និង អ្នកស្ម័គ្រចិត្ត

---

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា របស់សិស្សនៅលើ ឡានក្រុងសាលា, រួមមាន:
  - ចំនួនអតិបរិមានៃកុមារម្នាក់ ត្រូវបានអនុញ្ញាតិអោយ ក្នុងកៅអីមួយក្នុងឡាន។
  - ការប្រើប្រាស់ជួរឆ្លាស់គ្នា។
  - ពេលវេលាចាប់ផ្តើមរៀននៅសាលា ត្រូវបានរៀបចំបន្តបន្ទាប់គ្នា ដើម្បីអនុញ្ញាតអោយធ្វើដំណើរ ច្រើនជាងមួយជើង ក្នុងមួយឡាន នៅពេលចាប់ផ្តើម និងបិទសាលារៀន។

- ការអនុវត្តវិធានការណ៍នានា ដែលបង្ករលក្ខណៈងាយស្រួល សម្រាប់ឪពុកម្តាយក្នុងការដឹកសិស្ស ទៅសាលារៀន, ដូចជាមានវត្តមានបុគ្គលិកនាពេលបើកដំបូង, ចំណតរយៈពេលខ្លីនៅតាម សាលារៀនបានត្រូវពន្យាពេល, និងវត្តមានបុគ្គលិកនៅតាមតំបន់ទំលាក់/ដាក់សិស្សចុះ ដើម្បី ធានាបាននូវការធ្វើចលនារបស់សិស្ស ប្រកបដោយសុវត្ថិភាពពីកន្លែងទំលាក់ ទៅកាន់ច្រកចូល សាលារៀន។
- ការអនុវត្តនូវវិធានការណ៍នានា ដែលជួយសម្រួលដល់ការធ្វើដំណើររបស់សិស្ស ទៅសាលារៀន ប្រកបដោយសុវត្ថិភាព និងសមស្របទៅតាមអាយុ រួមទាំងក្រុមដើរតាមផ្លូវសុវត្ថិភាព ទៅកាន់ សាលារៀន, ការប្រើឆ្មាំឆ្លងកាត់សាលារៀន, ការរៀបចំកម្មវិធីសុវត្ថិភាពកង់ និងផ្លូវកង់។
    - ឪពុកម្តាយត្រូវបានចូលរួមពាក់ព័ន្ធ ក្នុងការធ្វើការជាមួយបុគ្គលិកសាលា ដើម្បីធានាថា ជម្រើសនៃការដឹកជញ្ជូនជំនួស ត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ និងបានដាក់បញ្ចូល យុទ្ធសាស្ត្រ សម្រាប់ការឃ្លាតឆ្ងាយរាងកាយពីគ្នា និងការប្រើប្រាស់គម្របមុខក្រណាត់។
- ហេដ្ឋារចនាសម្ព័ន្ធអាគារ ត្រូវបានកែសំរួល ដើម្បីទទួលបានការគាំទ្រអតិបរិមាសម្រាប់ដំណើរកង់ និងសមត្ថភាពសម្រាប់ផ្ទុកកង់ ត្រូវបានបង្កើនឡើង ប្រសិនបើអាចធ្វើទៅបាន។
- ផ្សេងៗ ____________________________________________________________

☐ វិធានការណ៍នានាត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅពេលដែលសិស្ស, ឪពុកម្តាយ ឬភ្ញៀវ មកដល់ផ្លូវចូលទៅកាន់សាលារៀន។ ទាំងនេះ រួមបញ្ចូលទាំង:

- សិស្សចេញពីឡានក្រុង ឬរថយន្តផ្សេងទៀត អោយរចេញចូលតាមទ្វារតែមួយ។
- បុគ្គលិកសាលារៀន ត្រូវបានដាក់ពង្រាយដើម្បីបំពេញតាមឡានក្រុង, ឡាន និងសិស្ស ដែល កំពុងបើកមកដល់ ដោយថ្មើរជើង ឬជិះកង់ ដើម្បីធានាថាចម្ងាយឆ្ងាយត្រូវបានរក្សា និងបញ្ចៀស នូវការប្រមូលផ្តុំគ្នា។
- បិទថេប ឬសញ្ញាសម្គាល់ផ្សេងទៀត ដើម្បីជួយសិស្សអោយរក្សានូវគម្លាតរាងកាយពីគ្នា នៅពេល ដែលពួកគេតម្រង់ជួរ ចូលសាលារៀន។
- ច្រកចូល និងច្រកចេញជាច្រើន ត្រូវបានប្រើប្រាស់ ដើម្បីជៀសវាងការមកដល់ និងការចាកចេញ ពីសាលារៀនលើសចំណុះ/កកកុញ ដរាបណាច្រកចូល និងច្រកចេញទាំងអស់ មានការត្រួតពិនិត្យគ្រប់គ្រាន់ ក្នុងការមកដល់ និងចាកចេញនៃសិស្ស និងនិយោជិក។
- ផ្សេងៗ ____________________________________________________________

- ☐ វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅពេលសិស្ស, ឪពុកម្តាយ ឬភ្ញៀវ ចូលនិងធ្វើដំណើរ តាមទីតាំងអាគារសាលារៀន។ ទាំងនេះ អាចរួមបញ្ចូលទាំង:
  - ○ និយោជិកសាលារៀន ត្រូវបានដាក់ពង្រាយនៅតាមផ្លូវដើរ ដើម្បីធានាដល់ការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅពេលសិស្សចូល, ឆ្លងកាត់ការត្រួតពិនិត្យរោគសញ្ញា និងបន្តទៅថ្នាក់រៀន។
  - ○ និយោជិកសាលារៀន ត្រូវបានដាក់ពង្រាយនៅតាមផ្លូវដើរ ពេញមួយថ្ងៃទៅតាមតម្រូវការ ដើម្បីធានាអោយដល់ការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅពេលដែលសិស្សផ្លាស់ពីថ្នាក់រៀនមួយ ទៅថ្នាក់រៀនមួយទៀត ឬពីថ្នាក់រៀនទៅកាន់ទីតាំងសាលារៀនផ្សេងទៀត។
  - ○ សមត្ថភាពជណ្តើរយន្ត, ប្រសិនបើអាចអនុវត្តបាន, ត្រូវបានកំណត់ចំពោះចំនួនមនុស្ស ដែលអាចសំរុះសំរួលផ្ទុក ខណៈពេលដែលរក្សាបានចម្ងាយ ៦ ហ្វីត រវាងអ្នកជិះទាំងឡាយ; ក្នុងកំឡុងពេលនៃការចូលអាគារ និងពេលចេញ ដែលមានមនុស្សច្រើនបំផុត, ចំនួននេះអាចត្រូវបានកែសំរួលដល់ចំនួនអតិបរិមានៃអ្នកជិះចំនួន ៤ នាក់ ក្នុងមួយលើក សំរាប់ជណ្តើរយន្តណាមួយ ដែលមិនអនុញ្ញាតអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា ចំនួន ៦ ហ្វីត រវាងអ្នកជិះ។ អ្នកជិះទាំងអស់ត្រូវពាក់គំម្របមុខក្រណាត់, លើកលែងតែ មានការលើកលែង ដូចបានចែងខាងលើ។
  - ○ វិធានការណ៍ខាងក្រោម បានធ្វើឡើង ដើម្បីជៀសវាងការប្រមូលផ្តុំគ្នា នៅលើជណ្តើរ:
    - ○ ការរៀបចំជណ្តើរឡើងលើ និងចុះក្រោម
    - ○ ការរៀបចំបន្តបន្ទាប់គ្នានៃពេលឈប់សម្រាក រវាងថ្នាក់
    - ○ ការត្រួតពិនិត្យជណ្តើរ ដោយបុគ្គលិកសាលា
    - ○ ផ្សេងៗ__________________________
- ☐ វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅក្នុងថ្នាក់រៀន។ ទាំងនេះ រួមបញ្ចូល (គូសធីកទាំងអស់ ដែលត្រូវ):
  - ○ ទំហំថ្នាក់រៀនផ្ទាល់ ត្រូវបានកំណត់ត្រឹមសិស្ស ចំនួន ___ នាក់ នៅក្នុងថ្នាក់បឋម។
  - ○ ទំហំថ្នាក់រៀនផ្ទាល់ ត្រូវបានកំណត់ត្រឹមសិស្ស ចំនួន ___ នាក់ នៅក្នុងថ្នាក់អនុវិទ្យាល័យ និងថ្នាក់វិទ្យាល័យ។
  - ○ ថ្ងៃសិក្សាត្រូវបានបែងចែកជាវេនៗ ដើម្បីអនុញ្ញាតិអោយសិស្សមានតិចជាងមុន ក្នុងមួយថ្នាក់។
  - ○ វត្តមានចូលរៀន គឺបានត្រូវដាក់អោយរៀនបន្តបន្ទាប់គ្នា ដើម្បីកាត់បន្ថយចំនួនសិស្សសរុប នៅក្នុងថ្នាក់រៀន នៅក្នុងមួយថ្ងៃៗ។

- ថ្នាក់ខ្លះ ត្រូវបានផ្លាស់ប្តូរទាំងស្រុង អោយរៀនតាមអ៊ីនធឺណែត។
- វត្តមានចូលរៀនក្នុងថ្នាក់តាមអ៊ិនធឺណែត ត្រូវបានផ្តល់ជូនជាជម្រើសសម្រាប់សិស្សទាំងឡាយណា ដែលអាចធ្វើទៅបាន និងសម្រាប់សិស្សដែលអាចមានហានិភ័យខ្ពស់ នៅក្នុងថ្នាក់រៀនធម្មតា។
- កន្លែងចំលាស់ ត្រូវបានប្រើ ដើម្បីកាត់បន្ថយចំនួនសិស្សនៅក្នុងថ្នាក់រៀន។ ទាំងនេះ អាចរួមបញ្ចូល:
  - បណ្ណាល័យសាលា
  - សាលប្រជុំ
  - ហាងកាហ្វេ
  - កន្លែងហាត់ប្រាណ
  - ទីធ្លាខាងក្រៅនានា
  - ផ្សេងៗ _____________
- គ្រឿងសង្ហារិមក្នុងថ្នាក់រៀន ត្រូវបានបង្កើតឡើង ដើម្បីធានាបាននូវចម្ងាយ ៦ ហ្វីត រវាងសិស្សនៅតុ/តុអង្គុយរបស់ពួកគេ និងរវាងសិស្ស និងគ្រូ (ការដាក់តុ/តុអង្គុយ, ការប្រើប្រាស់ផ្លាកសញ្ញាតាមឥដ្ឋ ដើម្បីបង្ហាញពីចំងាយដែលមានតំរូវការ ។ល។) តាមដែលអាចធ្វើទៅបាន។ កន្លែងដែលចម្ងាយ ៦ ហ្វីត មិនអាចធ្វើទៅបានទេនោះ, របាំងរាងកាយត្រូវបានប្រើ ដើម្បីកាត់បន្ថយទំនាក់ទំនងជិតស្និទ្ធ។
- គ្រឿងសង្ហារិមដែលត្រូវបានរចនាឡើងសម្រាប់សកម្មភាពក្រុមនៅក្នុងថ្នាក់រៀន ដែលនាំអោយសិស្សមានចំងាយជិតជាង ៦ ហ្វីត ត្រូវបានរៀបចំកំណត់រចនាសម្ព័ន្ធជាថ្មីឡើងវិញ ឬដកចេញពីថ្នាក់រៀន។
- តំបន់សំរាកមួយស្របក់ ឬកន្លែងសម្រាកនៅក្នុងថ្នាក់រៀន មានសិស្ស បានដាក់អោយមានចម្ងាយ ៦ ហ្វីតពីគ្នា ហើយឆ្លាស់ជើងទៅក្បាល។
- វិធីសាស្ត្របង្រៀនត្រូវបានផ្លាស់ប្តូរ ដើម្បីចៀសវាងការប្រាស្រ័យទាក់ទងគ្នាយ៉ាងជិតស្និទ្ធរវាងសិស្ស នៅក្នុងមន្ទីរពិសោធន៍ និងថ្នាក់ផ្សេងៗទៀត ដែលជាទូទៅអាចពាក់ព័ន្ធទៅនឹងសកម្មភាពជាក្រុម។
- ផ្សេងៗ
  ____________________________________________________________

- សកម្មភាពថ្នាក់ហាត់ប្រាណ ត្រូវបានជ្រើសរើស ដើម្បីអនុញ្ញាតិអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា ហើយគួរតែត្រូវបានគេធ្វើនៅខាងក្រៅ នៅពេលដែលអាចធ្វើទៅបាន ឬនៅពេលដែលត្រូវបានដាក់អណ្តតិ ដោយរដ្ឋ ឬបទបញ្ញាតាមតំបន់។
- គោលនយោបាយរបស់សាលា អនុវត្តនូវការឃ្លាតឆ្ងាយរាងកាយពីគ្នា (សិស្សរក្សាចម្ងាយ ៦ ហ្វីត) នៅក្នុងបន្ទប់ទ្បុកកើ/បន្ទប់ចាក់សោរ។ គោលនយោបាយ អាចរួមបញ្ចូលៈ
  - ផ្តល់នូវលទ្ធភាពចូលប្រើបន្ទប់ទ្បាក់កើ តែនៅពេលមានការត្រួតពិនិត្យ ពីបុគ្គលិកតែប៉ុណ្ណោះ
  - រៀបចំការចូលប្រើបន្ទប់ទ្បាក់កើ បន្តរបន្ទាប់គ្នា
  - បង្កើតជម្រើសជំនួសសម្រាប់ការផ្ទុកសម្លៀកបំពាក់, សៀវភៅ និងរបស់របរផ្សេងៗរបស់សិស្ស។
- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា អំឡុងពេលបរិភោគអាហារសាលា។ ទាំងនេះ អាចរួមបញ្ចូលៈ
  - ក្នុងកំរឹតដែលអាចធ្វើបាន, អាហារត្រូវបានបរិភោគនៅក្នុងថ្នាក់រៀន ឬខាងក្រៅ, ដោយមិនមានការលាយឡំបញ្ចូលគ្នារវាងសិស្សបឋមសិក្សា ពីថ្នាក់រៀនផ្សេងៗឡើយ។
  - ប្រសិនបើសិស្សតម្រង់ជួរដើម្បីទៅយកម្ហូបអាហារ, បិទបង់ស្ទីត ឬសញ្ញាសំគាល់ផ្សេងទៀត ដើម្បីធានាអោយបាននូវចំងាយ ៦ ហ្វីត រវាងរាល់សិស្សពីរនាក់។
  - បុគ្គលិកត្រូវបានដាក់ពង្រាយ ក្នុងកំឡុងពេលបរិភោគអាហារ ដើម្បីរក្សានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា និងរក្សាសិស្សសាលាបឋមសិក្សា ពីការលាយឡំបញ្ចូលគ្នា មកពីថ្នាក់ផ្សេងៗ។
  - ប្រសិនបើការបរិភោគ អាហារកើតឡើងនៅក្នុងហាងកាហ្វេ, ពេលវេលាបរិភោគអាហារ ត្រូវបានរៀបចំបន្តរបន្ទាប់គ្នា តាមកម្រឹតដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយចំនួនសិស្សនៅក្នុងហាងកាហ្វេ ក្នុងពេលតែមួយ; បុគ្គលិកត្រូវតែត្រៀម ដើម្បីធានាថាសិស្សសាលាបឋម មិនមានការលាយឡំបញ្ចូលគ្នា មកពីថ្នាក់ផ្សេងៗឡើយ។
  - ប្រសិនបើអាហារ កើតឡើង/ដាក់អោយបរិភោគនៅក្នុងហាងកាហ្វេ, ចន្លោះរវាងតុ/កៅអី ត្រូវបានបង្កើន ដើម្បីទ្រទ្រង់គំលាតចំងាយរាងកាយ ៦ ហ្វីត។ របាំងរវាងតុ និង/ឬកៅអី អាចត្រូវបានប្រើជាជម្រើស នៅពេលដែលចម្ងាយឆ្ងាយពីគ្នា ៦ ហ្វីត មិនអាចធ្វើទៅបាន។
- ការរៀបចំម្ហូបអាហារ និងប្រតិបត្តិការសេវាកម្ម ត្រូវបានរៀបចំឡើងវិញ, តាមដែលអាចធ្វើទៅបាន, ដើម្បីសម្រេចបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា រវាងនិយោជិក។ ឧទាហរណ៍, ផ្ទះបាយ និងផ្នែកខាងក្រោយនៃកម្រាលផ្ទះ បានត្រូវដាក់ជាសញ្ញាសំគាល់ ដើម្បីពង្រឹងនូវតម្រូវការគំលាតឆ្ងាយរាងកាយពីគ្នា។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 OR**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីអនុញ្ញាតិអោយមានគំលាតឆ្ងាយរាងកាយពីគ្នា នៅក្នុងតំបន់សាលារៀន ដែលត្រូវបានប្រើប្រាស់សម្រាប់សេវាកម្មគាំទ្រសិស្ស។
    - បុគ្គលិកគាំទ្រសិស្ស, រួមទាំងនិយោជិកសាលារៀន (គិលានុបដ្ឋាយិកា, អ្នកប្រឹក្សាយោបល់ណែនាំ, អ្នកព្យាបាលរោគ ។ល។) និងនិយោជិកនានានៃកម្មវិធីទ្រទ្រង់ជំនួយ (គ្រូពេទ្យ, អ្នកអប់រំសុខភាព ។ល។) ត្រូវបានណែនាំអោយរក្សាចម្ងាយរាងកាយយ៉ាងហោចណាស់ ៦ ហ្វីត តាមលទ្ធភាពដែលអាចធ្វើទៅបាន ក្នុងខណៈពេលដែលចូលរួមពាក់ព័ន្ធក្នុងសកម្មភាពគាំទ្រសិស្ស។
    - គ្រឿងសង្ហារិម និងគ្រឿងបរិក្ខារនៅតាមតំបន់សាលារៀន ត្រូវបានប្រើសម្រាប់សេវាកម្មគាំទ្រសិស្ស ត្រូវបានរៀបចំដើម្បីលើកកម្ពស់ នូវចម្ងាយ ៦ ហ្វីត រវាងសិស្សពីរនាក់ និង/ឬរវាងសិស្ស និងបុគ្គលិក។
    - នៅកន្លែងដែលអាចធ្វើទៅបាន និងសមស្រប, សកម្មភាពព្យាបាល និងគាំទ្រ ត្រូវបានអនុវត្តតាមបែបនិម្មិត
    - ជៀសវាងនូវការចែករំលែកឧបករណ៍ និងគ្រឿងផ្គត់ផ្គង់ ក្នុងករណីដែលអាចធ្វើទៅបាន។ ប្រសិនបើឧបករណ៍នោះ ចាំបាច់ត្រូវតែចែករំលែក, វាត្រូវតែបានធ្វើអនាម័យ មុន និងក្រោយការប្រើប្រាស់នីមួយៗ ដោយសិស្ស និង/ឬនិយោជិកផ្សេងៗគ្នា
    - បុគ្គលិកដែលផ្តល់សេវាកម្មគាំទ្រដល់សិស្ស ត្រូវបានផ្តល់ជូននូវ PPE សមស្របតាមតម្រូវការ Cal OSHA នានា។
- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីអនុញ្ញាតិអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា នៅក្នុងតំបន់រដ្ឋបាល នៃសាលារៀន
    - ស្លាកសញ្ញាប្រាប់ភ្ញៀវ អំពីតម្រូវការក្នុងការរក្សាចម្ងាយ ៦ ហ្វីត ពីបុគ្គលិកការិយាល័យសាលារៀន។
    - ត្រូវបិទថេប ឬសញ្ញាសំគាល់ផ្សេងៗ ដើម្បីកំណត់កាំចំងាយ ៦ ហ្វីតនៅជុំវិញតុ ឬខោនធើទទួលភ្ញៀវ។
    - កន្លែងធ្វើការរបស់បុគ្គលិករដ្ឋបាល ត្រូវបានគេរៀបចំអោយមានចម្ងាយ ៦ ហ្វីត រវាងបុគ្គលដែលចែករំលែកកន្លែងទំនេរ ឬរវាងបុគ្គលិកការិយាល័យ និងសិស្ស ឬបុគ្គលិកផ្សេងទៀត ដែលត្រូវការទៅទស្សនាកន្លែងនោះ។

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា និងអនុវត្តនូវការគ្រប់គ្រងការឆ្លងប្រកបដោយសុវត្ថិភាព នៅក្នុងសកម្មភាពសិក្សាមុខវិជ្ជាបន្ថែម។ ទាំងនេះ អាចរួមបញ្ចូលៈ
  - ព្រឹត្តិការណ៍អ្នកទស្សនាពេលនេះ មិនត្រូវបានអនុញ្ញាតិឡើយ; នេះរួមបញ្ចូលទាំងព្រឹត្តិការណ៍ខាងក្នុង និងខាងក្រៅ។
  - ក្រុមអត្តពលកម្មសិក្សាមុខវិជ្ជាបន្ថែម ដែលសាលាបានជ្រើសរើសបើកឡើងវិញ (បានកំរឹត ចំពោះកីឡានានា ដែលអនុញ្ញាតដោយបទបញ្ជារបស់រដ្ឋ ហើយដែលអនុញ្ញាតិអោយមាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា ដូចជាកីឡាតិន្និស, វាយកូនហ្គោល, សកម្មភាពកាយសម្ព័ន្ធ ដែលមិនតម្រូវអោយមានអ្នកមើល ។ល។) ត្រូវបានកំណត់ឡើងវិញ ជាការចាំបាច់ ដើម្បីបញ្ចូលនូវគំលាតឆ្ងាយរាងកាយពីគ្នា ចូលទៅក្នុងការហ្វឹកហ្វឺន និងការលេង។
  - ក្រុមកីឡាសិក្សាមុខវិជ្ជាបន្ថែម ដែលមិនអនុញ្ញាតិអោយឃ្លាតឆ្ងាយរាងកាយពីគ្នា (កីឡាបេសបល, ហ្វុតបល, បាល់ទាត់ ។ល។) មិនបានបើកដំណើរការឡើងវិញឡើយ។ ចំណាំថា គ្រូបង្វឹកអាចផ្តល់នូវកម្មវិធីកាយសម្បទា និងបង្កើតជំនាញដល់សិស្ស សម្រាប់ការប្រើប្រាស់របស់ពួកគេម្នាក់ៗ។
  - វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីបញ្ចៀសការប្រមូលផ្តុំនៃសិស្សដែលគ្មានការត្រួតពិនិត្យនៅក្នុងបន្ទប់ទឹក។ ទាំងនេះ អាចរួមបញ្ចូលៈ
    - ផ្តល់នូវលទ្ធភាពចូលប្រើបន្ទប់ទឹក តែនៅពេលមានការត្រួតពិនិត្យ ពីបុគ្គលិកតែប៉ុណ្ណោះ
    - រៀបចំការចូលប្រើបន្ទប់ទឹក បន្តរបន្ទាប់គ្នា
  - សកម្មភាពតន្ត្រីសិក្សាមុខវិជ្ជាបន្ថែម ត្រូវបានផ្លាស់ប្តូរទៅតាមអ៊ិនធឺរណិត ឬត្រូវបានកំណត់រចនាសម្ព័ន្ធឡើងវិញ ជាការចាំបាច់ ដើម្បីរួមបញ្ចូលនូវគំលាតឆ្ងាយរាងកាយពីគ្នា។
    - ក្រុមចំរៀង ឬសកម្មភាពណាមួយ ដែលតម្រូវនូវការច្រៀង ឬស្រែក/សូត្រ ត្រូវបានផ្អាក។
    - សកម្មភាពនានា ដែលមានការបង្កើននូវលទ្ធភាពសម្រាប់ការបញ្ជូន ពីការដែលបានបញ្ចេញតំណក់ទឹកតូចៗកខ្វក់ – ដូចជាការច្រៀង, ការស្រែក, ការសូត្រ, ឧបករណ៍ផ្លុំខ្យល់នានា – មិនត្រូវបានអនុញ្ញាតិទេ នៅពេលនេះ។
  - សកម្មភាពសិក្សាមុខវិជ្ជាបន្ថែមនានា ដែលមិនមែនជាអត្តពលកម្ម ឬតន្ត្រី (ក្រុម, ក្លឹប) ជួបតាមអ៊ិនធឺរណិត ជាជាងជួបដោយផ្ទាល់ តាមដែលអាចធ្វើទៅបាន។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 OR**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ព្រឹត្តិការណ៍ជួបដោយផ្ទាល់នានានៅទូទាំងសាលារៀន (ការជួបប្រជុំ, ការសម្តែងតាមសាលា ។ល។) និងការធ្វើដំណើរជាក្រុមទៅតាមទីវាល ត្រូវបានបញ្ឈប់។ ពួកគេអាចត្រូវបានធ្វើ តាមបែប និម្មិត។

## C. វិធានការណ៍នានា ដើម្បីធានាបាននូវ ការគ្រប់គ្រងការឆ្លង

- ការចំរាញ់/ត្រួតពិនិត្យ ត្រូវបានធ្វើឡើងមុនពេលសិស្ស, ភ្ញៀវ និងបុគ្គលិកអាចចូលសាលារៀន។ ការពិនិត្យ ត្រូវរាប់បញ្ចូលនូវការពិនិត្យ ឬការឆែកឆេរទាក់ទងនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬមានបទពិសោធន៍នៃជំងឺ គ្រុនក្តៅ និងរោគសញ្ញាផ្សេងនានាទៀត ដែលភ្ញៀវអាចនឹងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបាន ធ្វើពីចម្ងាយ (ដោយប្រើកម្មវិធីឌីជីថល ឬវិធីសាស្រ្តដែលអាចផ្ទៀងផ្ទាត់បានផ្សេងទៀត) ឬត្រួតពិនិត្យដោយ ផ្ទាល់ នៅពេលមកដល់។ ការត្រួតពិនិត្យសីតុណ្ហភាពជាមួយទែម៉ូម៉ែត្រដែលមិនប៉ះ ត្រូវបានបញ្ចូលក្នុងការ ពិនិត្យរោគសញ្ញា នៅពេលចូល ប្រសិនបើអាចធ្វើទៅបាន។
  - ភ្ញៀវ និងបុគ្គលិកពេញវ័យ ដែលចំរាញ់/ពិនិត្យឃើញវិជ្ជមាននៅពេលចូល ឬអ្នកដែលរាយការណ៍ រោគសញ្ញានានា នៅចំណុចណាមួយ ក្នុងពេលថ្ងៃសិក្សា ត្រូវបានណែនាំអោយត្រឡប់ទៅផ្ទះវិញ ហើយដាក់ខ្លួនឯងអោយនៅឯកោ ដូចដែលមានតម្រូវការ តាមបទបញ្ជារបស់មន្ត្រីសុខាភិបាល ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២០ (សូមមើលបទបញ្ជាមន្ត្រីសុខាភិបាល ដាក់ខ្លួនឯងអោយនៅឯកោ)។
  - សិស្ស ដែលចំរាញ់/ពិនិត្យឃើញវិជ្ជមាននៅពេលចូល ឬអ្នកដែលរាយការណ៍រោគសញ្ញានានា នៅ ចំណុចណាមួយ ក្នុងពេលថ្ងៃសិក្សា ត្រូវបានផ្តល់អោយនូវម៉ាស់វះកាត់ និងបានអមជាមួយ ទៅ កន្លែងដាច់ដោយឡែកមួយដែលបានជ្រើសរើសទុកជាមុន ជាទីដែលពួកគេអាចស្នាក់នៅ ក្នុង ខណៈពេលដែលរៀបចំ សម្រាប់ការវិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញ។
  - ក្រុមអនុលោមតាម COVID-19 (មើលផ្នែក A ទំព័រ ២) ត្រូវបានជូនដំណឹងអំពីលទ្ធផលនៃការ ពិនិត្យវិជ្ជមាន នៅក្នុងសាលារៀន និងផ្តួចផ្តើមផែនការគ្រប់គ្រងការប្រឈមការប្រឈមនឹងជំងឺ COVID-19 [ផែនការគ្រប់គ្រងការប្រឈមការប្រឈមនឹងជំងឺ COVID-19] ស្របតាមការណែនាំ របស់ LBDHHS។

- ○ ភ្ញៀវពេញវ័យ, បុគ្គលិក, សិស្ស, និងមនុស្សពេញវ័យផ្សេងៗទៀត ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយបុគ្គលដែលបានពិនិត្យឃើញវិជ្ជមាន ត្រូវបានណែនាំអោយត្រឡប់ទៅផ្ទះវិញ ដោយដាក់ខ្លួនឯងអោយនៅដាច់ឆ្ងាយដោយឡែក ដូចដែលមានតម្រូវការដោយ [បទបញ្ជាចត្តាឡីស័ក ឬអោយដាក់ខ្លួននៅដាច់ឆ្ងាយពីគេ របស់មន្ត្រីសុខាភិបាល](), រហូតទាល់តែដល់ពេលវេលាណានោះ ដែលត្រូវបានគេកំណត់ថា ការពិនិត្យទៅលើបុគ្គលដែលមានរោគសញ្ញាវិជ្ជមាននានា ចំពោះជំងឺ COVID-19 គឺអវិជ្ជមានចំពោះជំងឺ COVID-19។

- ការពិនិត្យលើមនុស្សពេញវ័យ និងសិស្សដែលមានអាយុថ្នាក់អនុវិទ្យាល័យ និងថ្នាក់វិទ្យាល័យ រួមមានសំណួរអំពីការទាក់ទងជិតស្និទ្ធជាមួយអ្នកណាម្នាក់នៅផ្ទះ, សាលារៀន ឬកន្លែងផ្សេងទៀត ដែលបុគ្គលនោះ ត្រូវបានគេប្រាប់ថាបានធ្វើតេស្តវិជ្ជមាន ចំពោះជំងឺ COVID-19។
  - ○ មនុស្សពេញវ័យណាម្នាក់ ដែលត្រូវបានគេពិនិត្យឃើញថាមានការប្រឈម និងរាយការណ៍ថាមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកមានជំងឺ ត្រូវបានគេណែនាំអោយចាកចេញពីសាលារៀន, ត្រឡប់ទៅផ្ទះវិញ ដើម្បីផ្តួចផ្តើមធ្វើចត្តាឡីស័ក/ដាក់ខ្លួនអោយនៅឆ្ងាយពីគេ, ហើយត្រូវធ្វើតេស្តរកមើលជំងឺ COVID-19។
  - ○ សិស្សថ្នាក់អនុវិទ្យាល័យ ឬវិទ្យាល័យណា ដែលត្រូវបានគេពិនិត្យឃើញថាមានការប្រឈម និងរាយការណ៍ថាមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកមានជំងឺ ត្រូវបានគេផ្តល់អោយនូវម៉ាស់វះកាត់ និងអមជាមួយ ទៅកាន់កន្លែងដែលបានកំណត់ទុកជាមុន នៅក្នុងសាលារៀន ក្នុងខណៈពេលដែលរៀបចំ សម្រាប់អោយឪពុកម្តាយរបស់ពួកគេមកទទួល ដើម្បីចាប់ផ្តើមនូវការដាក់ខ្លួនឯងអោយធ្វើចត្តាឡីស័កនៅផ្ទះ។ ឪពុកម្តាយត្រូវបានគេណែនាំ អោយស្វះស្វែងរកការធ្វើតេស្តលើកុមារ បន្ទាប់ពីថ្ងៃទី ១០ នៃការធ្វើចត្តាឡីស័ក របស់ពួកគេ។

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីកំរឹតហានិភ័យនៃការឆ្លង ដោយការមកសួរសុខទុក/មកលេងដោយបុគ្គលក្រៅពីបុគ្គលិក និងសិស្ស។ ទាំងនេះ អាចរួមបញ្ចូលៈ
  - ○ ការមកលេងសាលាដោយបុគ្គលក្រៅពីបុគ្គលិក និងសិស្ស ត្រូវបានជៀសវាង នៅពេលណាដែលអាចធ្វើទៅបាន។ ឪពុកម្តាយរបស់និស្សិតដែលបានចុះឈ្មោះ ត្រូវបានលើកទឹកចិត្ត អោយធ្វើការងារ/ជំនួញ ជាមួយបុគ្គលិកសាលាពីចម្ងាយ នៅពេលដែលអាចធ្វើទៅបាន។
  - ○ ភ្ញៀវ ទៅសាលារៀនក្រៅពីឪពុកម្តាយរបស់សិស្ស ដែលបានចុះឈ្មោះត្រូវបានកំណត់ចំពោះអ្នកដែលចាំបាច់ សម្រាប់ប្រតិបត្តិការរបស់សាលារៀន។ ភ្ញៀវ គឺតាមការណាត់ជួបតែប៉ុណ្ណោះ ហើយ

ត្រូវបានចុះឈ្មោះជាមុន នៅក្នុងសៀវភៅកំណត់ហេតុភ្ញៀវ ដែលរួមមានឈ្មោះ, លេខទូរស័ព្ទ និង អាស័យដ្ឋានអ៊ីម៉ែល របស់ភ្ញៀវ។ ភ្ញៀវត្រូវបានណែនាំ អោយមកកន្លែង ឬទីណាត់ជួបតែម្នាក់ឯង ប៉ុណ្ណោះ។ ប្រសិនបើភ្ញៀវ ត្រូវតែអមដំណើរដោយមនុស្សម្នាក់ទៀត (ឧទាហរណ៍ សម្រាប់ជំនួយ បកប្រែ, ឬដោយសារភ្ញៀវនោះ ជាអនីតិជន ឬមានសិស្សអនីតិជន) ព័ត៌មានរបស់ពួកគេ ត្រូវបាន កត់ត្រាជាប់ ក្នុងកំណត់ហេតុភ្ញៀវ។

- ភ្ញៀវមកដល់សាលារៀនជាមួយកុមារ ដែលមិនបានចុះឈ្មោះ (ឧទាហរណ៍ ប្អូនៗរបស់សិស្ស) ត្រូវធានាថា កុមារទាំងនេះ នៅជាប់នឹងមនុស្សពេញវ័យ, ជៀសវាងប៉ះពាល់ជាមួយនឹងមនុស្ស ផ្សេងទៀត ឬរបស់របរ ដែលមិនមែនជាកម្មសិទ្ធិរបស់ពួកគេ, ហើយត្រូវបានគេបិទ/ពាក់ម៉ាស់ ប្រសិនបើអាយុ ២ ឆ្នាំ ឬច្រើនជាង និងមិនមានហានិភ័យ ដោយសារតែលក្ខំណផ្លូវដង្ហើម។
- ចលនារបស់ភ្ញៀវនៅក្នុងសាលារៀន ត្រូវបានកំណត់ ចំពោះតែតំបន់ដែលបានកំណត់ទុក ដូចជា កន្លែងទទួលភ្ញៀវ ឬឡប់ប៊ី, ការិយាល័យ, សាលសន្និសិទ ឬបន្ទប់ប្រជុំ, និងបន្ទប់ទឹកសាធារណៈ ក្នុងកំរិតដែលអាចធ្វើទៅបាន។
- ភ្ញៀវត្រូវបានណែនាំថា ពួកគេត្រូវពាក់គម្របមុខក្រណាត់ គ្រប់ពេលវេលាទាំងអស់ ក្នុងខណៈ ពេលនៅក្នុងសាលារៀន។

- ☐ វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីលើកកំពស់អោយមានខ្យល់ចេញចូលល្អបំផុត នៅក្នុងសាលា រៀន។ ទាំងនេះ អាចរួមបញ្ចូល (គូសធីកទាំងអស់ ដែលត្រូវ):
  - ប្រព័ន្ធ HVAC របស់សាលាមានលក្ខ័ណ្ឌល្អ, និងនៅមានដំណើរការ។
  - ប្រព័ន្ធ HVAC ត្រូវបានកំណត់ ដើម្បីបង្កើនការផ្លាស់ប្តូរខ្យល់ខាងក្នុង/ខាងក្រៅ បានច្រើនបំផុត លុះត្រាតែលក្ខ័ណ្ឌខាងក្រៅ (អគ្គីភ័យថ្មីៗ, សីតុណ្ហភាពខាងក្រៅខ្ពស់, ចំនួនលំអងខ្ពស់ ។ល។) ធ្វើអោយមិនសមរម្យ។
  - ម៉ាស៊ីនសំអាតខ្យល់ ដែលអាចយកតាមខ្លួនបានប្រកបដោយប្រសិទ្ធភាពខ្ពស់ ត្រូវបានតំឡើង ប្រសិនបើអាចធ្វើទៅបាន។
  - ទ្វារ និងបង្អួចនានា ត្រូវបានរក្សាអោយបើក ក្នុងកំឡុងពេលថ្ងៃ ប្រសិនបើអាចធ្វើទៅបាន ហើយ ប្រសិនបើលក្ខ័ណ្ឌខាងក្រៅ ធ្វើអោយមានលក្ខណៈសមរម្យ។
  - តម្រងខ្យល់ ត្រូវបានធ្វើអោយប្រសើរឡើង អោយមានប្រសិទ្ធភាពខ្ពស់បំផុត តាមតែអាចធ្វើទៅ បាន។

- ផ្សេងៗ: ____________________________________________

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការសំអាតសមរម្យ និងការរំងាប់មេរោគនៅតាមកន្លែង, ផ្ទៃ និងវត្ថុនានា នៅទូទាំងសាលារៀន។ ទាំងនេះ អាចរួមបញ្ចូលៈ
  - កាលវិភាគសំអាត និងរំងាប់មេរោគ ត្រូវបានបង្កើតឡើង ដើម្បីជៀសវាង ផលិតផលសំអាត ដែលទាំងការប្រើប្រាស់តិចតួច និងការប្រើប្រាស់ហួសកំរិត។
  - ការសំអាតទីធ្លាសាលាឱ្យបានប្រសើរ ត្រូវបានធ្វើឡើងនៅពេលដែលនិស្សិត មិននៅសាលារៀន ដោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីទុកកន្លែងអោយបានត្រូវខ្យល់សំងួត មុនពេលចាប់ផ្តើមនៃថ្ងៃសិក្សា។
  - រថយន្តក្រុងសាលាត្រូវបានសម្អាត និងរំងាប់មេរោគយ៉ាងហ្មត់ចត់ជារៀងរាល់ថ្ងៃ និងក្រោយពេលដឹកជញ្ជូនបុគ្គលណាម្នាក់ ដែលកំពុងបង្ហាញរោគសញ្ញានានានៃជម្ងឺ COVID-19។ អ្នកបើកបរត្រូវបានបំពាក់អោយមាននូវក្រណាត់រំងាប់មេរោគ និងស្រោមដៃដែលអាចចោលបាន ដើម្បីគាំទ្រដល់ការរំងាប់មគលើផ្ទៃនានា ដែលមានតម្រូវការ នៅពេលដំណើរការបើកបរ។ ផ្ទៃដែលបានប៉ះជាញឹកញាប់ ត្រូវបានរំងាប់មេរោគ បន្ទាប់ពីផ្លូវឡានក្រុងសាលា ត្រូវបានបញ្ចប់។
  - តំបន់ទូទៅ និងវត្ថុដែលត្រូវបានប៉ះពាល់ជាប្រចាំ នៅក្នុងតំបន់ទាំងនោះ (តុ, ដៃទ្វារ, កុងតាក់ភ្លើង, ខោនធើថប, ដៃបើកបិទ/ទ្វារ, តុ, ទូរស័ព្ទ, ក្តារចុច, ឧបករណ៍ចុចប្តូរជាន់ក្នុងជណ្តើរយន្ត និងប៊ូតុងផ្សេងៗ, អេក្រង់ប៉ះ, ម៉ាស៊ីនព្រីនធ័រ/ម៉ាស៊ីនថតចំលង, ដៃសំរាប់ចាប់/កាន់យក, បង្កាន់ដៃជណ្តើរ) ត្រូវបានរំងាប់មេរោគ យ៉ាងតិចជារៀងរាល់ថ្ងៃ ហើយជាញឹកញាប់ តាមដែលមាននូវធនធាននានា ដែលអនុញ្ញាតិអោយប្រើប្រាស់នូវផលិតផលសមស្របនានា (មើលខាងក្រោម)។
  - ការប្រើប្រាស់របស់របរចែករំលែក ត្រូវបានលុបចោល នៅពេលដែលអាចធ្វើទៅបាន, ឧទាហរណ៍ បិទកន្លែងក្បាលរ៉ូប៊ីណេទឹក ហើយផ្តល់អោយជាជំរើសជំនួស ដោយផ្តល់ដបទឹកបុគ្គលនីមួយៗ, ឧបករណ៍នៅកន្លែងលេងដែលប៉ះពាល់ច្រើន អាចត្រូវបានយកចេញកុំអោយមានការប្រើប្រាស់ ហើយដាក់ជំនួសមកវិញ នូវកន្លែងហ្គេមលេងនានា ដែលគ្មានការប៉ះពាល់ ។ល។
  - នៅពេលដែលជំរើសជាលក្ខណៈបុគ្គលមិនអាចធ្វើទៅបាន, ឧទាហរណ៍, នៅក្នុងបន្ទប់ពិសោធន៍ និងបន្ទប់សិល្បៈ ដែលឧបករណ៍ខ្លះអាចត្រូវបានប្រើដោយសិស្ស, វត្ថុ/របស់របរ និងផ្ទៃជាច្រើន/នានា ត្រូវបានសំអាត និងរំងាប់មេរោគ រវាងអ្នកប្រើប្រាស់ទាំងឡាយ។

- ផលិតផលសំអាត ដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺ COVID-19 (ទាំងនេះត្រូវបានដាក់រាយនៅលើបញ្ជី "N" ដែលបានអនុម័តដោយទីភ្នាក់ងារការពារបរិស្ថាន (EPA) ត្រូវបានប្រើប្រាស់ស្របតាមការណែនាំផលិតផល។
- ដើម្បីកាត់បន្ថយផលិតផលនានា ដែលមានហានិភ័យនៃជំងឺហឺត ដែលមាននៅក្នុងបញ្ជីលេខ N ជាមួយនឹងគ្រឿងផ្សំដែលមានសុវត្ថិភាពច្រើនជាងពីជំងឺហឺត (អ៊ីដ្រូសែនភេរ៉ុស៊ែដ, ស៊ីទ្រីចអាស៊ីត ឬឡាក់ទិកអាស៊ីត) ត្រូវបានជ្រើសរើស។ ផលិតផលដែលមានអាស៊ីតភេរ៉ូស៊ីយ៉ាសេទិច peroxyacetic (ភេរ៉ាសេទិច peracetic), សូដ្យូមហ៊ីប៉ូក្លរ៉ៃដ៍ hypochlorite (ប្លីឆ bleach) ឬសមាសធាតុអាម៉ូញ៉ូមខ្វ័រធើនេរី quaternary ត្រូវបានជៀសវាង។
- អ្នកថែទាំ និងបុគ្គលិកដទៃទៀត ដែលទទួលខុសត្រូវក្នុងការសំអាត និងរំងាប់មេរោគផ្ទៃ និងរបស់របរ/វត្ថុសាលារៀន ត្រូវបានបណ្តុះបណ្តាលអំពីការណែនាំរបស់អ្នកផលិត, តំរូវការនានារបស់ Cal/OSHA សំរាប់ការប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងទៅតាមតំរូវការ បទបញ្ជាសាលារៀនសុខភាពល្អ, ដែលអាចអនុវត្តបាន។
- អ្នកថែទាំ និងបុគ្គលិកដទៃទៀត ដែលទទួលខុសត្រូវក្នុងការសំអាត និងរំងាប់មេរោគ ត្រូវបានបំពាក់ដោយឧបករណ៍ការពារផ្ទាល់ខ្លួនសមស្រប, រួមមានស្រោមដៃ, ការពារភ្នែក, ការពារផ្លូវដង្ហើម និងឧបករណ៍ការពារសមស្របផ្សេងទៀត ទៅតាមតម្រូវការរបស់ផលិតផល។
- រាល់ផលិតផលសម្អាតទាំងអស់ត្រូវបានទុកដាក់ អោយឆ្ងាយពីដៃរបស់កុមារ និងបានត្រូវរក្សាទុកក្នុងកន្លែងដែលមានដាក់កំរឹតក្នុងការចេញចូល។
- ខ្យល់ចេញចូល ត្រូវបានពង្រីក/បង្កើអោយដល់កំរឹតអតិបរមា ក្នុងកំឡុងពេលសំអាត និងរំងាប់មេរោគ ក្នុងកំរិតដែលអាចធ្វើទៅបាន, ប្រសិនបើប្រើម៉ាស៊ីនត្រជាក់, សូមប្រើការកំណត់/សេតធីងដែលនាំយកមកនូវខ្យល់អាកាសបរិសុទ្ធ។ ជំនួស និងពិនិត្យប្រព័ន្ធត្រង/តំរង និងប្រព័ន្ធត្រងខ្យល់នានា ដើម្បីធានាបាននូវគុណភាពខ្យល់ល្អប្រសើរបំផុត។
- បង្កើននូវការសំអាតទីធ្លាសាលាអោយបានប្រសើរ នៅពេលដែលសិស្សមិននៅសាលារៀន ដោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីទុកអោយទីកន្លែងនោះត្រូវខ្យល់/ស្ងួតដោយសារខ្យល់ មុនពេលចាប់ផ្តើមនៃថ្ងៃសិក្សា។

- ត្រូវអនុវត្តនូវជំហ៊ាននានា ដើម្បីធានាថាប្រព័ន្ធទឹក និងស្តុកទឹកទាំងអស់ មានសុវត្ថិភាពក្នុងការប្រើប្រាស់ បន្ទាប់ពីការបិទទីកន្លែងនោះរយៈពេលយូរ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺរលាកសួត Legionnaires និងជំងឺផ្សេងៗដទៃទៀត ដែលទាក់ទងនឹងទឹក។
- បន្ទប់ទឹក, ឡប់ប៊ី, បន្ទប់សំរាក, និងកន្លែងសំរាក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានរំងាប់មេរោគជាញឹកញាប់, រួមបញ្ចូលនូវៈ
    - បន្ទប់ទឹក
    - តំបន់ឡបប៊ី/ចូល
    - បន្ទប់សំរាកគ្រូ/បុគ្គលិក
    - ថ្នាក់រៀន
    - តំបន់បរិភោគកាហ្វេ
    - តំបន់រៀបចំម្ហូបអាហារកាហ្វេ
    - ការិយាល័យខាងមុខ
    - ការិយាល័យផ្សេងៗ
    - តំបន់ផ្សេងៗទៀត

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការប្រើប្រាស់គម្របមុខសមស្របដោយបុគ្គលិក, សិស្ស និងភ្ញៀវ គ្រប់ពេលវេលាទាំងអស់។ ទាំងនេះ អាចរួមបញ្ចូលៈ
    - បុគ្គលិក, ឪពុកម្តាយ និងសិស្ស ត្រូវបានជូនដំណឹងអំពីតម្រូវការសម្រាប់ការបិទបាំងគម្របមុខក្រណាត់ មុនពេលចាប់ផ្តើមសាលា និងជាប្រចាំពេញមួយឆ្នាំសិក្សា។
    - សិស្សទាំងអស់ ដែលមានអាយុលើសពី ២ ឆ្នាំ តំរូវអោយពាក់គម្របមុខក្រណាត់ គ្រប់ពេលវេលាទាំងអស់ ខណៈពេលនៅក្នុងទ្រព្យសម្បត្តិសាលារៀន លើកលែងតែពេលកំពុងបរិភោគ, ផឹក ឬធ្វើសកម្មភាពនានាផ្សេងទៀត ដែលរារាំងនូវការប្រើប្រាស់គម្របមុខ។
        - យុទ្ធសាស្រ្តការពារជំនួស អាចត្រូវបានអនុម័តឡើង ដើម្បីសំរុះសំរួលសិស្ស ដែលមានការអប់រំលក្ខណៈបុគ្គល (IEPs) ឬផែនការ ៥០៤ ហើយនឹងអ្នកដែលមិនអាចប្រើប្រាស់ ឬអត់ទ្រាំនឹងការបិទបាំងគម្របមុខក្រណាត់បាន។
    - ព័ត៌មានត្រូវបានផ្តល់ជូនបុគ្គលិក, ឪពុកម្តាយ និងសិស្ស ទាក់ទងទៅនឹងការប្រើប្រាស់គម្របមុខក្រណាត់ អោយបានត្រឹមត្រូវ រួមទាំងតំរូវការក្នុងការបោកសំអាតគម្របមុខក្រណាត់ បន្ទាប់ពីប្រើមួយថ្ងៃៗ។

- ស្លាកសញ្ញានៅឯច្រកចូលសាលារៀន, នៅច្រកចូលការិយាល័យលាលារៀន និងនៅទូទាំងអាគារសាលារៀន ពង្រឹងនូវតំរូវការនេះ និងបង្ហាញអំពីការប្រើប្រាស់ត្រឹមត្រូវ នៃការបិទបាំងគម្របមុខក្រណាត់។
- តាមដែលអាចធ្វើបាន, គម្របមុខក្រណាត់ចំនួនពីរ ត្រូវបានផ្តល់ជូនដល់សិស្សម្នាក់ៗ នៅពេលចាប់ផ្តើមនៃឆ្នាំសិក្សា។ ប្រសិនបើវាមិនអាចធ្វើទៅបានទេនោះ, ឪពុកម្តាយ និងសិស្ស ត្រូវបានផ្តល់ព័ត៌មានដែលទាក់ទងនឹងវិធីសាស្រ្តនានា សំរាប់ធ្វើនូវគម្របមុខក្រណាត់ផ្ទាល់ខ្លួនរបស់ពួកគេ។
- ឪពុកម្តាយនៃកុមារតូចៗ ត្រូវបានលើកទឹកចិត្តអោយផ្តល់គម្របមុខទីពីរ សំរាប់សាលារៀនរៀងរាល់ថ្ងៃ ក្នុងករណីដែលគម្របមុខទីមួយរបស់កុមារ មានការប្រឡាក់ប្រឡូស; នេះនឹងអនុញ្ញាតិអោយផ្លាស់ប្តូរគម្របមុខ ក្នុងកំឡុងថ្ងៃនោះ។
- បុគ្គលិកដែលត្រូវបានគេដាក់ពង្រាយ នៅផ្លូវចូលសាលា ឬនៅច្រកផ្លូវដើរ ឬតំបន់ទូទៅផ្សេងទៀត ដើម្បីពង្រឹងនូវគំលាតឆ្ងាយរាងកាយពីគ្នា ផងដែរ ក៏រំលឹកកសិស្សអំពីច្បាប់នានា ទាក់ទងនឹងការប្រើប្រាស់គម្របមុខក្រណាត់។
- និយោជិកដែលមានការពាក់ព័ន្ធ ក្នុងសកម្មភាពនានា (ដូចជា ការផ្តល់នូវការព្យាបាលរាងកាយ ឬជំនួយផ្ទាល់ខ្លួនទៅដល់សិស្សម្នាក់ៗ) ដែលមិនអាចអនុញ្ញាតឱ្យមានការឃ្លាតឆ្ងាយរាងកាយពីគ្នា ត្រូវបានបំពាក់ដោយឧបករណ៍ការពារផ្ទាល់ខ្លួនសមស្រប (ស្រោមដៃ, ម៉ាស់ ជាដើម ។ល។) តាមការសមរម្យ ដែលអាចធ្វើទៅបាន។
- បុគ្គលិកដែលមើលថែសិស្សដែលឈឺ ត្រូវបានគេផ្តល់អោយនូវម៉ាស់កំរឹតវេជ្ជសាស្រ្ត ដើម្បីពាក់ខ្លួនឯង, និងម៉ាស់កំរឹតវេជ្ជសាស្រ្តសម្រាប់អោយសិស្សពាក់ (ប្រសិនបើអាចស៊ូទ្រាំបាន) រហូតដល់សិស្សនោះ ចាកចេញពីអាគារ។

**សំគាល់:** បុគ្គលិក និងសិស្ស ដែលនៅម្នាក់ឯងនៅក្នុងការិយាល័យដែលបានបិទទ្វារ, គូបដែលមានបិទជញ្ជាំង ឬកន្លែងឯកជន, កន្លែងផ្សេងៗដែលបិទជុំវិញ មិនតម្រូវឱ្យពាក់គម្របមុខក្រណាត់ឡើយ។ ផងដែរ សិស្សក៏អាចដោះគម្របមុខក្រណាត់ចេញបានដែរ នៅពេលបរិភោគ ឬគេងមួយស្របក់ ឬបើមិនដូច្នេះទេ ក្នុងពេលដែលមិនអាចអនុវត្តបាន នូវការពាក់គម្របមុខ (ឧទាហរណ៍ ពេលងូតទឹក ជាដើម ។ល។)។ សាលារៀន អាចពិចារណា ថាតើវាសមរម្យឬទេ សំរាប់គ្រូនៅថ្នាក់ដំបូង/ថ្នាក់កុមារតូចៗ ក្នុងការប្រើខែលរបាំងមុខប្លាស្ទិច ដោយប្រើក្រវ៉ាត់បិទនៅក្រោម

ចង្ការ ជាការជំនួសអោយគម្របមុខក្រណាត់ ដើម្បីឱ្យសិស្សក្មេងៗជាងគេ បានឃើញមុខគ្រូរបស់ពួកគេ និងជៀសវាង នូវសក្តានុពលឧបស័គ្គ ក្នុងការបង្រៀនតាមសូរស័ព្ទ។

- វិធានការណ៍នានា ត្រូវបានធ្វើឡើង ដើម្បីធានាបាននូវការលាងដៃអោយបានញឹកញាប់ ដោយបុគ្គលិក, សិស្ស និងភ្ញៀវទាំងឡាយ។ ទាំងនេះ អាចរួមបញ្ចូលៈ
  - សិស្ស និងបុគ្គលិក បានត្រូវផ្តល់ឱកាសអោយលាងដៃរបស់ពួកគេ រយៈពេល ២០ វិនាទី, ជាមួយសាប៊ូ, ត្រដុសយ៉ាងហ្មត់ចត់ បន្ទាប់ពីដាក់លើដៃ, ហើយប្រើកន្សែងក្រដាស់ (ឬកន្សែងក្រណាត់ដែលប្រើតែម្តងគត់) ដើម្បីធ្វើអោយដៃស្ងួតយ៉ាងហ្មត់ចត់។
  - សិស្សក្មេងៗ ត្រូវបានកំណត់ពេលវេលាពេលសំរាក សំរាប់ការលាងដៃអោយបានញឹកញាប់ជាប្រចាំ, រួមមាន មុន និងក្រោយពេលបរិភោគអាហារ, បន្ទាប់ពីប្រើប្រាស់បង្គន់, បន្ទាប់ពីលេងនៅខាងក្រៅ, និងមុន និងក្រោយ សកម្មភាពក្រុមណាមួយ។
  - បុគ្គលិកត្រូវបានណែនាំអោយធ្វើជាគំរូ នៃការលាងដៃញឹកញាប់, ជាពិសេសនៅថ្នាក់ទាប ដែលពេលវេលានៃបន្ទប់ទឹក គឺជាឱកាសដើម្បីពង្រឹងទម្លាប់ដែលមានសុខភាពល្អ និងត្រួតពិនិត្យ ការលាងដៃអោយបានត្រឹមត្រូវ។
  - ស្ថានីយ៍លាងដៃចល័ត ត្រូវបានគេដាក់នៅក្បែរថ្នាក់រៀននានា ដើម្បីកាត់បន្ថយចលនា និងការប្រមូលផ្តុំនៅបន្ទប់ទឹកអោយបានតិចបំផុត តាមដែលអាចធ្វើទៅបាន។
  - ដាក់អោយមាននូវ ទឹកធ្វើអនាម័យដៃដែលមានជាតិអាល់កុលអេទីល សម្រាប់សិស្ស និងបុគ្គលិក នៅទីតាំងយុទ្ធសាស្ត្រនៅទូទាំងសាលារៀន ដែលមិនមានកន្លែងស្នូកទឹក ឬស្ថានីយ៍លាងដៃចល័ត (នៅក្នុង ឬជិតបន្ទប់រៀន, បន្ទប់ដែលផ្តល់សេវាកម្មគាំទ្រ, បន្ទប់តន្ត្រី និងបន្ទប់សិល្បៈ)។ អាល់កុលអេទីល ត្រូវបានគេពេញចិត្ត ហើយគួរតែត្រូវបានប្រើប្រាស់ដោយកុមារ នៅពេលមានសក្តានុពលនៃការប្រើប្រាស់ដែលមិនមានការត្រួតពិនិត្យ។ ទឹកធ្វើអនាម័យដៃអាយសូប្រូផីលមានជាតិពុលច្រើន ហើយអាចស្រូបចូលតាមស្បែក។
  - ទឹកធ្វើអនាម័យដៃ ដោយផ្អែកលើជាតិអាល់កុលអាយសូប្រូផីល មិនត្រូវបានប្រើប្រាស់នៅក្នុងសាលារៀនឡើយ ដោយសារសក្តានុពលនៃជាតិពុលរបស់វា ហើយទឹកធ្វើអនាម័យដៃ មិនត្រូវបានដាក់អោយប្រើ ឬមាននៅក្នុងថ្នាក់រៀនកុមារ ដែលមានអាយុក្រោម ៩ ឆ្នាំឡើយ។ មហាវិទ្យាល័យ និងបុគ្គលិក ត្រូវបានជូនពត៌មានអោយដឹង អំពីហានិភ័យនៃការលេបចូល ហើយពួកគេត្រូវ

តែទូរស័ព្ទទៅកាន់ ការត្រួតពិនិត្យជាតិពុល តាមលេខ ១-៨០០-២២២-១២២២ ប្រសិនបើមាន ហេតុផលជឿជាក់ថា សិស្សនោះបានបរិភោគទឹកផ្សែអនាម័យដៃ។
  - មាននូវទឹកផ្សែដៃអនាម័យ, សាប៊ូ និងទឹក, ក្រដាស់ជូតទន់ស្ដើង និងធុងសំរាម សម្រាប់សាធារណៈជន នៅ ឬជិតច្រកចូលកន្លែង/សាលា, កន្លែងទទួលភ្ញៀវ និងកន្លែងផ្សេងទៀត នៅក្នុកន្លែងធ្វើការ ឬនៅខាងក្រៅកន្លែងជាបន្ទាន់ ដែលមនុស្សមានអន្តរៈកម្មដោយផ្ទាល់។

- ☐ វិធានការណ៍នានា ត្រូវបានធ្វើឡើងដើម្បីធានាបាននូវ ការគ្រប់គ្រងការឆ្លង នៅក្នុងហាងកាហ្វេ/អាហារដ្ឋាន សាលារៀន ឬកន្លែងផ្សេងទៀត ដែលអាហារត្រូវបានបរិភោគ ឬបញ្ជូនអោយ/ទទួលយក។
  - អាហារប៊ូហ្វេ និងអាហារបែបគ្រួសារ ត្រូវបានលុប/បំបាត់ចោល។
  - ជម្រើសអាហារ រួមមានអាហារដែលបានខ្ចប់ជាកញ្ចប់, អាហារក្ដៅបម្រើដោយបុគ្គលិកអាហារដ្ឋាន និង/ឬអាហារដែលបានយកមកជាមួយដោយសិស្ស មកពីផ្ទះ។
  - កំណត់អោយមាននូវការរាំងខាងរាងកាយ ដើម្បីកំរឹត/កំណត់ការទំនាក់ទំនងរវាងបុគ្គលិកអាហារដ្ឋាន/ហាងកាហ្វេ និងសិស្ស។
  - ស្រេចលើចិត្ត - ពិពណ៌នាវិធានការណ៍ផ្សេងៗទៀត ______________________________

---

## D. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សហគមន៍សាលារៀន និងសាធារណៈជន

---

- ☐ ព័ត៌មានត្រូវបានផ្ញើទៅឳពុកម្ដាយ និងសិស្សមុនពេលចាប់ផ្ដើមសាលារៀន ទាក់ទងទៅនឹងគោលនយោបាយសាលារៀន ដែលពាក់ព័ន្ធនឹង:
  - គោលនយោបាយដាក់ខ្លួនអោយនៅឯកោ និងធ្វើចត្តាឡីស័ក នៅពេលពួកគេអនុវត្តចំពោះសិស្ស ដែលមានរោគសញ្ញា ឬបានត្រូវប្រឈម/ប៉ះពាល់ជាមួយនឹងជំងឺ COVID-19។
  - ជំរើសសំរាប់ការធ្វើតេស្តជំងឺ COVID-19 ប្រសិន បើសិស្ស ឬសមាជិកគ្រួសារ មានរោគសញ្ញា ឬបានត្រូវប្រឈម/ប៉ះពាល់ជាមួយនឹងជំងឺ COVID-19។
  - តើអ្នកណាត្រូវទាក់ទងនៅសាលា ប្រសិនបើសិស្សមានរោគសញ្ញានានា ឬអាចត្រូវបានប្រឈម/ប៉ះពាល់។
  - របៀបធ្វើការត្រួតពិនិត្យរោគសញ្ញា មុនពេលសិស្សចេញពីផ្ទះ។

- តម្រូវការ នៃការប្រើប្រាស់គម្របមុខ។
- សារៈសំខាន់របស់សិស្ស ក្នុងការអនុលោមតាមគោលនយោបាន ឃ្លាតឆ្ងាយរាងកាយពីគ្នា និង គោលនយោបាយគ្រប់គ្រងការឆ្លង។
- ការផ្លាស់ប្តូរកម្មវិធីសិក្សា និងកម្មវិធីមុខវិជ្ជាសិក្សាបន្ថែម ដើម្បីបញ្ចៀសហានិភ័យ
- ការផ្លាស់ប្តូរអាហារនៅសាលារៀន ដើម្បីបញ្ចៀសហានិភ័យ
- គោលនយោបាយសាលារៀន ទាក់ទងទៅនឹងការមកជួប/ទស្សនារបស់ឪពុកម្តាយនៅសាលារៀន និងការផ្តល់យោបល់អោយទំនាក់ទំនងសាលារៀន ពីចម្ងាយ
- សារៈសំខាន់នៃការផ្តល់អោយសាលារៀន នូវព័ត៌មានទំនាក់ទំនងបន្ទាន់ទាន់សម័យ រួមទាំងជម្រើសទំនាក់ទំនងឪពុកម្តាយច្រើនយ៉ាង។
- ផ្សេងៗ:__________________________________________________

☐ ច្បាប់ថតចំលងនៃពិធីសារនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលសាធារណៈ ទៅកាន់សាលារៀន។

☐ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅទូទាំងសាលារៀន ដើម្បីរំលឹកដល់បុគ្គលិក និងសិស្ស អំពីគោលនយោបាយនានា ដែលទាក់ទងនឹងការឃ្លាតឆ្ងាយរាងកាយពីគ្នា, ការប្រើប្រាស់គម្របមុខ, និងសារៈសំខាន់នៃការលាងដៃ។

☐ ស្លាកសញ្ញាត្រូវបានបិទផ្សាយ នៅតាមច្រកចូលសាធារណៈនីមួយៗនៃសាលា ជូនដំណឹងដល់ភ្ញៀវ ថាពួកគេមិនគួរចូលទៅក្នុងកន្លែងនោះឡើយ ប្រសិនបើពួកគេមានរោគសញ្ញានានា នៃជំងឺ COVID-19។

☐ សាលាបានបង្កើត និងបានផ្សព្វផ្សាយនូវផែនការទំនាក់ទំនង ក្នុងករណីមានការបិទពេញលេញ ឬបិទដោយផ្នែកខ្លះ ដោយសារមានចង្កោម នៃជំងឺ COVID-19 ដែលអាចកើតឡើង។

☐ ការចែកចាយព័ត៌មានតាមអ៊ិនធឺណែត/អនឡាញអៅឡែតរបស់សាលា (វេបសាយ, ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។) ផ្តល់ជូននូវព័ត៌មានច្បាស់លាស់, និងទាន់ហេតុការណ៍ អំពីម៉ោងអាគារ, គោលការណ៍នៃការមកទស្សនា, ការផ្លាស់ប្តូរកម្មវិធីសិក្សា និងកម្មវិធីសិក្សាមុខវិជ្ជាបន្ថែម, និងតំរូវការទាក់ទងនឹងការប្រើប្រាស់គម្របមុខ, ការឃ្លាតឆ្ងាយរាងកាយពីគ្នា និងការលាងដៃ។

☐ ការចែកចាយព័ត៌មានតាមអ៊ិនធឺណែត/អនឡាញអៅឡែត ណែនាំសិស្ស, ឪពុកម្តាយ និងគ្រូ អំពីវិធីទាក់ទងសាលារៀន ក្នុងករណីមានការឆ្លង ឬប្រឈម/ប៉ះពាល់។

## E. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ផែនការសម្រាប់ការធ្វើបច្ចុប្បន្នភាពផែនការអប់រំលក្ខណៈបុគ្គល (IEPs) និងផែនការ ៥០៤ របស់សិស្ស ដែលមានតម្រូវការពិសេស ត្រូវបានបង្កើតឡើង ដើម្បីធានាបានថា ការអប់រំអាចបន្តដោយគ្មានគ្រោះថ្នាក់ មិនប្រក្រតី ដល់សិស្ស។
  - ផែនការនេះរាប់បញ្ចូលទាំង វិធីសាស្ត្រសម្រាប់ទំនាក់ទំនងសាលារៀនយ៉ាងសកម្ម ជាមួយឪពុកម្តាយ នៅដើមឆ្នាំសិក្សា ដើម្បីធានាថា បញ្ហានានាដែលទាក់ទងនឹងការអប់រំ និងសុវត្ថិភាពរបស់កុមារ ត្រូវបានដោះស្រាយ។
  - ការកែសំរួលកម្មវិធី IEP ផ្ទាល់ខ្លួនបុគ្គល និងផែនការ ៥០៤ អាចពាក់ព័ន្ធនឹងការរៀនសូត្រពីចម្ងាយ, ការកែសំរួលថ្នាក់រៀន ដើម្បីសំរុះសំរួល ទៅនឹងតម្រូវការរបស់សិស្ស, វត្តមានសាលារៀននៅតំបន់ដាច់ដោយឡែក ដែលមានសិស្សតិច, ឬវិធីសាស្ត្រកូនកាត់មួយ ដែលច្របាច់រួមបញ្ចូលគ្នា រវាងថ្នាក់រៀន និងការរៀនពីចំងាយ។
  - ជំហ៊ាននានា ត្រូវបានអនុវត្ត ដើម្បីកែសំរួលកម្មវិធី IEPs និងផែនការ ៥០៤ ដើម្បីធានាបាននូវសុវត្ថិភាពសិស្ស អនុលោមទៅតាមបទប្បញ្ញត្តិ/ខចែងពាក់ព័ន្ធនានា នៃច្បាប់រដ្ឋ និងសហព័ន្ធ។
- សេវាកម្មរដ្ឋបាល ឬប្រតិបត្តិការនានា ដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ (ឧទាហរណ៍ ការចុះឈ្មោះថ្នាក់, ការបញ្ជូនទម្រង់ ជាដើម ។ល។) ត្រូវបានផ្លាស់ប្តូរ ដាក់នៅលើអ៊ីនធឺណិត។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់រាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

**ឈ្មោះទំនាក់ទំនងសាលា: ______________________ លេខទូរស័ព្ទ: _________________________**

**កាលបរិច្ឆេទកែប្រែចុងក្រោយ: __________________________**

**ដើម្បីរាយការណ៍ការចំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 OR**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**